

# អាថ៌កំបាំងនៃហិង្សាផ្លូវភេទ
# ក្រោមរបបខ្មែរក្រហម

ឌួង សាវ៉ន

មិថុនា -២០១១

# អាថ៌កំបាំងនៃហិង្សាផ្លូវភេទ

## ក្រោមរបបខ្មែរក្រហម

ដួង សាវ៉ន

មិថុនា -២០១១

ជាបឋមខ្ញុំបាទសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធលោកឪពុករបស់ខ្ញុំ ឈ្មោះ ដួង វ៉ន ដែលត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់នៅចុងឆ្នាំ១៩៧៥។ ខ្ញុំសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះផ្នែកហិង្សាផ្លូវភេទ និងជនរងគ្រោះដទៃទៀតដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមទាំងអស់ឱ្យរួចចាកផុតសេចក្ដីទុក្ខទាំងឡាយទាំងពួង។ ខ្ញុំសូមបួងសួងសូមឱ្យអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ឆាប់ទទួលបានយុត្តិធម៌ និងធូរស្បើយពីការឈឺចាប់នានាចាប់ពីពេលនេះតទៅ។

# មាតិកា

ទីតាំងភូមិសាស្ត្រនៃការសម្ភាសន៍ជនរងគ្រោះ និងសាក្សីក្រោមរបបខ្មែរក្រហមក្នុងសៀវភៅនេះ




| ទីកន្លែង | ឈ្មោះ | ទំព័រ |
|---|---|---|
| បាត់ដំបង | ទឹម ទូច | ៤៨ |
| ពោធិ៍សាត់ | ឈួន សុង | ៦ |
| កោះកុង | លាង កន | ២០ |
| | យ៉េន អាំណាស | ៥២ |
| កំពង់ស្ពឺ | ប្រាក់ យឺន | ៤៤ |
| | មាស គឹម ឆន | ១៨ |
| កំពត | ទង កែវ | ៥០ |
| | មា ទីកាស | ៣០ |
| កណ្ដាល | សុន ពៅ | ៤២ |

| ទីកន្លែង | ឈ្មោះ | ទំព័រ |
|---|---|---|
| ភ្នំពេញ | លី វិជ្ជុតា | ២៨ |
| ព្រៃវែង | គង់ វណ្ណា | ១២ |
| តាកែវ | អ៊ិន ប៊ិច | ១៤ |
| | សែប ភាព | ៤០ |
| កំពង់ចាម | ណាំ ម៉ុន | ២៤ |
| | សាត ភាព | ៣៨ |
| ស្វាយរៀង | ជឹម សំអឿន | ១០ |
| | នេត សារឿន | ៣៤ |
| | ស៊ឹម សេដ្ឋា | ៣២ |

# អារម្ភកថា

ក្នុងសម័យសង្គ្រាមរវាងកងទ័ពខ្មែរក្រហម និងកងទ័ពសេនាប្រមុខ លន់ នល់ ខ្មែរក្រហមបានឃោសនាថារបបកុំមុយនិស្តរបស់ពួកគេមានសីលធម៏ខ្ពស់ជាពិសេសរឿងផ្លូវភេទ គេចាត់ទុកថាជារឿងខុសសីលធម៏ធ្ងន់ធ្ងរបំផុត រហូតត្រូវប្រហារជីវិតថែមទៀតផង។ ប៉ុន្តែតាមការពិសោធន៍ជាក់ស្តែងផ្ទាល់របស់ខ្ញុំនិងតាមការស្រាវជ្រាវរបស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជារបស់យើងខ្ញុំយើងបានរកឃើញថាការអះអាងទាំងនោះ គឺជាការឃោសនាភូតកុហកទាំងស្រុង។ ការបង្ខំឱ្យរៀបការដោយសំអាងថា អង្គការជាម៉ែឪ ដែលពេលខ្លះបង្ខំឱ្យនារីរូបស្អាតរៀបការនឹងយោធិនពិការ ត្រូវបានប្រើជាគោលការណ៍ផ្លូវការនៅទូទាំងប្រទេស។ នារីដែលត្រូវយោធា ឬឈ្លបខ្មែរក្រហមយកទៅសម្លាប់ ពួកវាខ្លះយកឈើចាក់រុកឆ្អឹះឆ្អៀលកេ្តីភេទរបស់ជនរងគ្រោះជាការសើចសប្បាយថែមទៀតផង។ ករណីខ្លះ កម្មាភិបាលខ្មែរក្រហមបានរំលោភនារីហើយនៅពេលនារីមានផ្ទៃពោះ រឺ ខ្លាចបែកការ គេក៏យកនារីនោះទៅសម្លាប់។

ប៉ុន្តែនៅពេលនោះ និងក្រោយរបបខ្មែរក្រហមរលំផុតទៅ រឿងរ៉ាវទាំងនោះភាគច្រើនត្រូវបានលាក់បាំង ដោយការខ្មាសអៀន ដោយការមិនចង់រំលឹកដែលនាំអោយមានការឈឺចាប់។ ដើម្បីបង្ហាញពីមុខមាត់ពិតរបស់របបកុំមុយនិស្តខ្មែរក្រហមអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា សម្រេចធ្វើការស្រាវជ្រាវពាក់ព័ន្ធនឹងការបំពានផ្លូវភេទក្រោមរបបខ្មែរក្រហម។ ក្រោយពីការស្រាវជ្រាវរបបខ្មែរក្រហម គឺមានអំពើបំពានផ្លូវភេទជាច្រើនដូចរបបផ្តាច់ការនានាដែរ។

រឿងហេតុទាំងឡាយដែលលើកឡើងនៅក្នុងសៀវភៅនេះ គឺជារឿងពិត ដែលគ្រាន់តែអ្នកនិពន្ធសូមលាក់ អត្តសញ្ញាណរបស់តួអង្គតែប៉ុណ្ណោះ។ សៀវភៅនេះមិនមានបំណងបើកកកាយរឿងអាថ៌កំបាំងរបស់រូបវន្តបុគ្គលណាម្នាក់នោះទេ គឺគ្រាន់តែចង់បង្ហាញមុខមាត់ពិតរបស់របបកុំមុយនិស្តខ្មែរក្រហមតែប៉ុណ្ណោះ ហើយក៏មិនមែនដើម្បីរំលឹករឿងធ្វើឱ្យជនរងគ្រោះមានការឈឺចាប់នោះដែរ។

សង្ឃឹមថា អ្នកអាននឹងកាន់តែស្វែងយល់ពីរបបកុំមុយនិស្តខ្មែរក្រហមកាន់តែច្បាស់ និងរួមគ្នាកុំឱ្យរបបបែបនេះមានជាលើកទីពីរលើទឹកដីកម្ពុជា។

ភ្នំពេញ, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១១

**នាយកប្រតិបត្តិ**

**មេធាវី សុក សំអឿន**

# សេចក្តីផ្តើម

នៅពេលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំមានអាយុត្រឹម១២ឆ្នាំប៉ុណ្ណោះ។ ខ្ញុំមិនយល់អ្វីប៉ុន្មានទេនៅពេលនោះខ្ញុំដឹងតែធ្វើការ និងស្រេកឃ្លានរាល់ថ្ងៃ។ ប៉ុន្តែខ្ញុំធ្លាប់ឃើញសាកសពក្នុងរណ្តៅ និងនៅរាយប៉ាយជាញឹកញាប់ ហើយខ្ញុំគ្រាន់តែយល់ថានៅជុំវិញខ្លួនខ្ញុំពិតជាមានការសម្លាប់មនុស្ស។ អារម្មណ៍របស់ខ្ញុំពេលនោះមិនមានអ្វីចម្លែកប៉ុន្មានទេ តែហេតុអ្វីខ្ញុំនៅតែនឹកឃើញ រឿងទាំងនោះរហូតមក។ ខ្ញុំជឿថាអារម្មណ៍របស់ជនរងគ្រោះដែលត្រូវគេធ្វើបាប និងសាក្សីដែលបានឃើញហេតុការណ៍ផ្ទាល់នានាពិតជានៅជិតដាមជាមួយនឹងរឿងទាំងនោះជាមិនខាន។

ក្រៅពីនោះ ខ្ញុំបានដឹងអំពីការឱ្យរៀបការរបស់ខ្មែរក្រហម។ ក្រោយពីបែកពីឪពុករបស់ខ្ញុំ ម្តាយរបស់ខ្ញុំត្រូវខ្មែរក្រហមបង្ខំឱ្យរៀបការនៅឆ្នាំ១៩៧៦ ហើយប្អូនស្រីបង្កើតរបស់គាត់ម្នាក់ក៏ខ្មែរក្រហមបង្ខំឱ្យរៀបការដែរ។ ខ្ញុំធ្លាប់ចែករំលែករឿងជាច្រើនជាមួយកូនៗរបស់ខ្ញុំ អំពីរបបខ្មែរក្រហម តែពួកគេមិនទាន់ដឹងថា ជីដូនរបស់គេសព្វថ្ងៃក៏ត្រូវខ្មែរក្រហមបង្ខំឱ្យរៀបការដែរទេ។ រឿងរ៉ាវដែលខ្ញុំនិយាយពេលនេះ ខ្ញុំចង់ចូលរួមជាមួយជនរងគ្រោះនានាដែលខ្ញុំកំពុងសរសេរអំពីរឿងរ៉ាវរបស់ពួកគាត់។ ខ្ញុំពិតជាមានមោទនភាពដោយបានចូលរួមជួយអ្នកដែលគេបង្ខំឱ្យរៀបការដាក់ពាក្យបណ្តឹង ទៅកាន់សាលាក្តីខ្មែរក្រហម ទោះបីមិនមានវត្តមានម្តាយខ្ញុំក្នុងនោះក៏ដោយ។ ក្រៅពីនេះខ្ញុំរីករាយ ដោយសាលាក្តីបានស៊ើបអង្កេតនៅទូទាំងប្រទេស និងទទួលស្គាល់ករណីការបង្ខំឱ្យរៀបការនេះ។

ពីដំបូងឡើយខ្ញុំយល់ថា អំពើហិង្សាផ្លូវភេទនៅរបបខ្មែរក្រហមប្រហែលមិនកើតមានទេ។ ពេលខ្ញុំបានអានសៀវភៅសិក្សារបស់លោកស្រី កាស៊ូមិ ណាកាហ្គាវ៉ា អំពីហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមជាលើកដំបូង ខ្ញុំមានការចាប់អារម្មណ៍ច្រើនលើប្រធានបទនេះ។ ហើយពេលខ្ញុំជួបជនរងគ្រោះ និងសាក្សីដែលដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីខ្មែរក្រហម ខ្ញុំកាន់តែជឿថា អំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមពិតជាកើតមានច្រើនយ៉ាង និងស្ទើរគ្រប់ទីកន្លែង។

មូលហេតុដែលយើងមិនសូវបានដឹងពីរឿងរ៉ាវទាំងនេះខ្ញុំយល់ថា ទាំងជនរងគ្រោះ និងសាក្សីពិបាកនិយាយរឿងនេះចេញមកអាចជាការខ្មាសអៀន និងជារឿងផ្ទាល់ខ្លួន។ ម្យ៉ាងទៀតរឿងទាំងនេះវាបានកើតឡើងជាង៣០ឆ្នាំមក ហើយយើងក៏ពុំមានការស្រាវជ្រាវ និងនិយាយលើប្រធានបទនេះដែរ។ លើសពីនេះទៀតយើងមិនសូវមានឱកាសនិយាយអំពីប្រវត្តិសាស្ត្រមួយនេះឱ្យបានទូលំទូលាយដូចពេលនេះឡើយ។ ខ្ញុំសង្ឃឹមថា សៀវភៅអាថ៌កំបាំងនៃហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម អាចជាព័ត៌មានសំខាន់មួយរួមចំណែកក្នុងការបំភ្លឺអំពីប្រវត្តិសាស្ត្រក្រោមរបបខ្មែរក្រហមដល់សាធារណជនទូទៅរួមទាំងអ្នកឆ្លងកាត់របបនោះ និងជាពិសេសសំរាប់មនុស្សជំនាន់ក្រោយ។

ខ្ញុំសូមអភ័យទោស ប្រសិនបើមានពាក្យពេចន៍ខុសឆ្គងដោយអចេតនាក្នុងសៀវភៅនេះ។ ខ្ញុំបាទរង់ចាំទទួលមតិទិតៀនរិះគន់ស្ថាបនាពីសំណាក់លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់។

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១

**ដួង សាវ៉ន**

# សាវតាររឿង

ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបហាយនភាពរយៈពេលជាង៣ឆ្នាំចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ គេស្គាល់ថាជារបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ឬក៏របបប៉ុល ពត។ ពាក្យថា "របបខ្មែរក្រហម "ត្រូវបានប្រើនៅក្នុងសៀវភៅនេះ។ របបខ្មែរក្រហមបានដឹកនាំប្រទេសបែបកុម្មុយនិស្តផ្តាច់ការ។ ប្រជាជនត្រូវរស់នៅប្រមូលផ្តុំទៅតាមភេទ តាមវ័យ និងត្រូវតែគោរពនិងដើរតាមអង្គការ ដោយគ្មានលក្ខ័ណ្ឌក្នុងគោលដៅបំរើបដិវត្តន៍ដ៏ឆ្កួតឆ្កៅរបស់គេ។ អង្គការ គឺសំដៅលើការដឹកនាំកំពូលរបស់ខ្មែរក្រហមដែលគ្មានរូប និងគួរឱ្យខ្លាចបំផុត។ របបនេះបានលុបបំបាត់ទាំងស្រុងគ្រប់ជំនឿសាសនា គ្មានចាយប្រាក់កាស និងគ្មានសាលារៀន។ ផ្ទុយទៅវិញខ្មែរក្រហម បានប្រែក្លាយទីវត្តព្រះវិហារ សាលារៀន ទៅជាមន្ទីរឃុំឃាំងសំរាប់ការធ្វើទារុណកម្ម និងសម្លាប់មនុស្ស។ ប្រជាជនត្រូវជម្លៀសចេញពីទីក្រុង និងបង្ខំឱ្យធ្វើការជាទម្ងន់ ខ្លះត្រូវស្លាប់ដោយអត់បាយ ដោយជម្ងឺ ដោយការធ្វើទារុណកម្ម និងកាប់សម្លាប់ឥតត្រាប្រណីជារៀងរាល់ថ្ងៃ។ ប្រជាជនប្រហែលជិត២លាននាក់បានស្លាប់ក្រោមរបបនេះ។ លើសពីនោះ ខ្មែរក្រហមក៏បានប្រើហិង្សា និងទារុណកម្មខាងផ្លូវភេទមកលើប្រជាជនជាច្រើននាក់ រួមទាំងរឿងការបង្ខំឱ្យរៀបការផងដែរ។ ទោះបីជាជាង៣០ឆ្នាំកន្លងទៅហើយក៏ដោយ ក៏នៅមានជនរងគ្រោះ និងសាក្សីមួយចំនួនដែលនៅរស់រានមានជីវិត មានសេចក្តីក្លាហាននិយាយរឿងទាំងនោះនៅក្នុងសៀវភៅនេះដែរ។

សព្វថ្ងៃនេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅថាសាលាក្តីខ្មែរក្រហម បាននិងកំពុងដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបខ្មែរក្រហម។ តុលាការនេះបង្កើតឡើងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិដែលមានជនជាតិខ្មែរ និងបរទេសចំរុះជាតិសាសន៍ចូលរួម។ ទន្ទឹមនឹងនេះអ្នកនៅរស់រានពីរបបខ្មែរក្រហមបានដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីនេះប្រមាណ ៨.២០២ លើសំណុំរឿង០០២។ ដោយឡែកតុលាការក៏បានស៊ើបអង្កេតលើរឿងការបង្ខំឱ្យរៀបការ និងបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៦៤ លើករណីមួយនេះផងដែរ។

ទោះបីសាលាក្ដីខ្មែរក្រហមកំពុងដំណើរការកាត់ទោសមេដឹកនាំ និងអ្នកទទួលខុសត្រូវទាំងនោះ តែការរំពឹងទុកក្នុងការទទួលយុត្តិធម៌របស់ជនរងគ្រោះទាំងអស់នោះមិនទាន់ប្រាកដប្រជានៅឡើយ។ ម្យ៉ាងទៀតពិតមែនតែសាលាក្ដីនេះបានស៊ើបអង្កេតលើករណីការរំលោភផ្លូវភេទនៅក្នុងរបបនោះ តែមិនបានភ្ជាប់ទៅការទទួលខុសត្រូវចំពោះមេដឹកនាំជាន់ខ្ពស់ទាំងនោះទេ ហើយជនរងគ្រោះក៏មិនបានដឹងអំពីការស៊ើបអង្កេតនូវរឿងរ៉ាវទាំងនោះដែរ។ ការជជែកពីការពិតនិងទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមទាំងមូល និងដោយឡែកចំពោះជនរងគ្រោះផ្នែកហិង្សាផ្លូវភេទនៅក្រៅតុលាការក៏អាចជាប្រយោជន៍ធ្វើឱ្យធូរស្រាលផ្នែកផ្លូវចិត្តរបស់ពួកគាត់ផងដែរ។

ចាប់តាំងពីសាលាក្ដីខ្មែរក្រហមផ្ដើមដំណើរការ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានចូលរួមគាំទ្រ និងផ្ដល់មេធាវីជូនជនរងគ្រោះនៅក្នុងរបបនោះតាំងពីដើមរៀងមក។ នៅដើមឆ្នាំ២០០៩កន្លងទៅ អង្គការនេះបានផ្ដួចផ្ដើមឱ្យមាននូវគំរោង អំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម។ គោលបំណងនៃគំរោងនេះគឺដើម្បីផ្ដល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះផ្នែកហិង្សាផ្លូវភេទដោយការរំលោភ ការបង្ខំឱ្យរៀបការ និងដើម្បីផ្ដល់ការយល់ដឹងជាសាធាណៈពីអំពើហិង្សាផ្លូវភេទដែលបានកើតឡើងក្នុងរបបខ្មែរក្រហមកន្លងមក។ ហេតុនេះ សៀវភៅអាថ៌កំបាំងនៃហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមដែលលោកអ្នកកំពុងអានក៏បានលេចចេញជារូបរាងឡើង។

រឿងអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម មិនសូវមានការស្រាវជ្រាវឬចងក្រងច្រើនទេកន្លងមក។ សៀវភៅ នេះជាឯកសារសម្រាប់ការស្វែងយល់របស់អ្នកសិក្សានានា សាធារណជនទូទៅ និងមនុស្សជំនាន់ក្រោយបានយល់ដឹងលើ ប្រធានបទដ៏កំរមួយនេះ។ ទាំងសាក្សី និងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទពិតជាមានការពិបាកនឹងនិយាយចេញមកណាស់ដោយការខ្មាសអៀន និងការឈឺចាប់របស់ពួកគាត់។ ពិតណាស់ពួកគាត់គួរត្រូវបានគោរព គាត់ពិតជាមានសេចក្ដីក្លាហានក្នុងការចែករំលែករឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួនសំរាប់មនុស្សទូទៅ។ ព័ត៌មានទាំងឡាយក្នុងសៀវភៅនេះ បានមកពីការផ្ដល់ការសម្ភាសន៍ដោយស្ម័គ្រចិត្តរបស់ជនរងគ្រោះ និងសាក្សីផ្ទាល់។ ពួកគាត់បានត្រូវពន្យល់យ៉ាងច្បាស់លាស់ពីគោលបំណងនៃការចងក្រងសៀវភៅនេះ។ រឿងមួយចំនួនក្នុងសៀវភៅនេះជនរងគ្រោះត្រូវបានប្រើឈ្មោះក្លែង ឬគ្មានរូបថតគឺតម្រូវទៅតាមបំណងរបស់ពួកគាត់។

# ឈួន សុង

អាយុ ៩៤ឆ្នាំ បច្ចុប្បន្នរស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ជាខ្មែរកម្ពុជាក្រោម មានមុខរបរជាកសិករ មុនរបបខ្មែរក្រហមបួសជាសង្ឃ រហូតខ្មែរក្រហមផ្សឹក គាត់រៀបការប្រពន្ធទី២មានកូនទាំងអស់៥នាក់

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម



លោក ឈួន សុង បានរៀបការជាលើកដំបូងនៅក្នុងឆ្នាំ១៩៧៧។ គាត់ត្រូវមេកងប្រាប់ថាឱ្យគាត់យកប្រពន្ធទៅប្រយ័ត្នគេយកទៅវ៉ាយថ្ម។ ការយកទៅវ៉ាយថ្មមានន័យថា យកទៅសម្លាប់តាមគាត់យល់។ ការពិតគាត់មិនទាន់ចង់បានប្រពន្ធអ្វីទេ។ នៅរបបនោះគេឱ្យគាត់ធ្វើរទេះ រកត្រី ជីកប្រឡាយ និងប្រើរទេះធ្វើស្រែ និងដឹកសំភារៈផ្សេងៗ។ គាត់បានឃើញការសម្លាប់មនុស្សសរុបប្រហែលមួយពាន់នាក់នៅឃុំអូតាប៉ោង ស្រុកបាកានរវាងឆ្នាំ១៩៧៧ និង១៩៧៨ និងឃើញការរំលោភផ្លូវភេទជាច្រើនករណីពីក្រុមខ្មែរក្រហម។ ពួកគេទាំងនោះជាប្រជាជនថ្មី និងអ្នកដែលទើបជម្លៀសមកពីខេត្តស្វាយរៀង។ ជនរងគ្រោះមានក្មេងចាស់ស្រីប្រុស ទាំងគ្រួសារៗត្រូវគេសម្លាប់មួយលើកៗ មានពី៥០ទៅ១០០នាក់។ គាត់បានរៀបរាប់ពីហេតុការណ៍មួយចំនួនដូចខាងក្រោម។

ការសម្លាប់ គេច្រើនឱ្យប្រុសៗអង្គុយមួយជុំ ស្រីៗ និងក្មេងៗអង្គុយមួយជុំ។ គេចាប់ចងប្រុសៗ ហើយសម្លាប់មុនស្រីៗ និងក្មេងសម្លាប់ជាក្រោយ។ ស្រីៗត្រូវគេឱ្យស្រាតនៅខ្លួនទទេ។ គេតែងឱ្យស្រាតរបៀបនេះដើម្បីប្រមូលខោអាវ និងសំភារៈមានតំលៃដែលនៅជាប់នឹងខ្លួនជនរងគ្រោះ។ ស្ត្រីមានផ្ទៃពោះក៏ឃើញមានគេសម្លាប់ដែរ។ ចំពោះការរំលោភគាត់ថា មានស្ត្រីម្នាក់នោះត្រូវគេរំលោភហើយរត់មកឱ្យគាត់ជួយទាំងរាងកាយស្រាតននលតែគាត់មិនហ៊ានជួយទេ។ គាត់ថាស្ត្រីក្រមុំត្រូវគេរំលោភគ្មានលើកលែងឡើយ។ ពួកគេចង់រំលោភមួយណាស្រេចតែចិត្តគេ រំលោភបូកក៏មានដែរ។ តែមានអ្នកខ្លះគេចេះពិចារណាគេមិនធ្វើដូច្នោះទេ។ គាត់បាននិយាយពីការរំលោភមុនសម្លាប់មួយទៀតថា មានមនុស្សវ័យចំណាស់ម្នាក់ត្រូវជាឪពុកប្រធានសហករណ៍ បានដឹកដៃគាត់ទៅប្រាប់ថា:" ឯងមកណេះ! ឯងនេះមិនដឹងខ្យល់អីទេ! ចាំអញប្រាប់ថាអាមួយណានៅក្រមុំ មួយណាមានប្តីរួចហើយ"។ បុរសចំណាស់នោះបានយកមេជើងទៅរុកប្រដាប់ភេទស្ត្រីទាំងនោះ ដែលដេកដំរៀបគ្នានៅផ្ទាល់នឹងដីឱ្យគាត់មើលរួចពោលទៀតថា "អាក្អូន មីនេះធ្លាប់មានប្តី មានកូនហើយ មីនេះមិនទាន់ដែលមានទេ..."។



## លោក ឈួន សុង





លោក សុង បាននិយាយពី ករណីមួយផ្សេងទៀតថា គេបានកាត់ប្រដាប់ភេទបុរសម្នាក់ទាំងរស់យកទៅដាក់ចូលក្នុងប្រដាប់ភេទស្ត្រីម្នាក់ផ្សេងទៀតដែលនៅរស់ដែរ រួចយកកូនឈើរុកថែមទៀតផង។ ចំពោះជនល្មើសវិញក្នុងការសម្លាប់មួយលើក២ មានគ្នាប្រហែលពី១០ទៅ២០នាក់។ គាត់ថា អ្នកប្រព្រឹត្តខ្លះប្រហែលជាស្លាប់ហើយ តែក៏អាចមានអ្នកនៅរស់ខ្លះដែរ។ គាត់ក៏មិនដឹងថា គេនៅទីណា យើងមិនបាច់រៀបរាប់ឈ្មោះគេទេ។ គាត់បានឃើញហេតុការណ៍ទាំងនោះដោយគាត់ជាអ្នកបររទេះមានគ្នា៣នាក់គេចាត់ឱ្យដើរប្រមូល និងដឹកសំភារ:ខោអាវរបស់ជនរងគ្រោះទាំងនោះ។ ចំពោះអ្នកដឹកជញ្ជូនជាមួយគាត់ ២នាក់ទៀត គាត់មិនដឹងថា គេរស់នៅទីណាទេ។ សួរថា តើរូបគាត់ផ្ទាល់ដែលធ្លាប់បានប្រព្រឹត្តអ្វីដូចខាងលើទេ? គាត់ថាសុំអោយតែរស់នោះណាស់ហើយ។

## អារម្មណ៍ និងការចងចាំ

មនុស្សយើងបានកើតមកនេះជាកុសលធំណាស់ ចុះហេតុអ្វីត្រូវគេធ្វើបាបបែបនេះ ជាពិសេសមកលើស្រ្តី។ គាត់ថាមនុស្សយើងមិនត្រូវគេធ្វើបាបយ៉ាងនេះទេ លើសពីសត្វធាតុទៅទៀត អ្នកប្រព្រឹត្តទាំងនោះមិនសមជាមនុស្សទេ។ គាត់ធ្លាប់និយាយប្រាប់ជនជាតិបារាំងម្នាក់មានអ្នកខ្លះឃំពេលនោះ។ គាត់ក៏ធ្លាប់និយាយប្រាប់អ្នកផ្សេងៗទៀតដែរ តែចំពោះអ្នកឆ្លងកាត់របបខ្មែរក្រហមគេជឿរឿងទាំងនោះ។ ចំពោះក្មេងៗជំនាន់ក្រោយនេះប្រហែលមិនសូវជាជឿប៉ុន្មានទេ។ ដើម្បីចងចាំរឿងទាំងនេះគឺត្រូវតែចងក្រងវាទុក ហើយត្រូវយកទៅអប់រំ ឬផ្សព្វផ្សាយទៀត។ ការនិយាយរឿងនេះចេញមក គឺជាព័ត៌មានសំរាប់មនុស្សទូទៅ និងជំនាន់ក្រោយៗ។



# ជឹម សំអឿន

អាយុ៥១ឆ្នាំ មានប្តីមានកូន៣នាក់ សព្វថ្ងៃរស់នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ធ្វើស្រែនិងលក់ដូរនៅផ្ទះ

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រី សំអឿន រស់នៅស្រុកខាងលើដដែលធ្វើការក្នុងកងកុមារចល័ត។ ថ្ងៃមួយពេលគាត់ឈឺត្រូវសំរាកនៅមន្ទីរពេទ្យនៅភូមិឈើទាលនៅក្បែរមន្ទីរសន្តិសុខមួយ គាត់បានឃើញអំពើហិង្សាផ្លូវភេទមកលើនារីម្នាក់រស់នៅភូមិជាមួយគាត់។ នារីនោះឈ្មោះមុំ អាយុប្រហែល២០ឆ្នាំ ប្រជាជនថ្មីជាកូនទាហានថ្នាក់ខ្ពស់ម្នាក់របស់របបលន់ នល់។

នៅម៉ោងប្រហែលជាង៦ល្ងាច គាត់បានចេញទៅបត់ជើងតែម្នាក់ឯងនៅក្បែរកន្លែងគាត់សំរាក។ គាត់ឃើញឈ្លប មានគ្នា៤នាក់បណ្តើរនារីឈ្មោះមុំមកកាន់ព្រៃឈើទាលក្បែរនោះដែរ។ មកដល់ទីនោះគាត់ឃើញគេចាប់ដោះខោអាវនារីឈ្មោះមុំ ក្នុងគោលបំណងរំលោភ តែនារីនោះមិនព្រម និងមានការតដៃជាខ្លាំងជាមួយពួកគេ។ គេក៏ចាប់ចង និងញ៉ុកមាត់នារីមុំ បន្ទាប់មកគេចាក់សាំងដុតលើនារីមុំតែម្តង។ ខណៈនោះគាត់ខំយកក្រមាខ្ទប់មាត់គាត់ ហើយត្រឡប់មកកន្លែងវិញយ៉ាងស្ងៀមស្ងាត់។ គាត់មិនហ៊ាននៅតាមដានរឿងនោះទេ ហើយមិនដឹងថាសពនោះមានសភាពយ៉ាងណាដែរ។ គាត់ភ័យពេក ក្រោយមកគាត់សុំគេចេញពីពេទ្យនោះទៅកងកុមារវិញ។ បីថ្ងៃក្រោយមកគាត់ដឹងថាគេយកម្តាយនារីមុំនោះសម្លាប់ទៀត។

ចំពោះឈ្លបទាំង៤នាក់នោះគាត់ស្គាល់២នាក់ជាមេ គេឈ្មោះផាន់ ម្នាក់ទៀតឈ្មោះអឿន ពួកគេមានអាយុប្រហែល ៤០ឆ្នាំ។ ចំពោះ២នាក់ទៀតមានវ័យក្មេងគាត់មិនចាំឈ្មោះគេទេ។ ចុងឆ្នាំ១៩៧៨ គេបានចាប់ឈ្មោះផាន់ និងឈ្មោះអឿនទៅបាត់ ហើយគាត់ក៏មិនដឹងថាសព្វថ្ងៃពួកគេនោះមានវាសនាយ៉ាងណាដែរ។

## អារម្មណ៍ និងការចងចាំ

ខណៈគាត់ឃើញហេតុការណ៍នោះគាត់រន្ធត់ជាខ្លាំង និងនៅចងចាំរឿងនោះរហូត។ ក្រោយហេតុការណ៍នោះកើតឡើងភ្លាមគាត់បានលបខ្សឹបប្រាប់មិត្តជិតដិតគាត់ម្នាក់ដែរ និងក្រោយៗគាត់មកបាននិយាយប្រាប់អ្នកភូមិដែលបានស្គាល់នារី មុំ។ គាត់មានអារម្មណ៍ធូរស្រាលដោយការនិយាយរឿងទាំងនោះប្រាប់គេឯង ហើយគាត់អាចទាំងនិយាយរឿងគេធ្វើបាបឪពុកគាត់ប្រាប់គេបានផងដែរកាលពីមុនឡើយគាត់មិនមានសេចក្តីក្លាហាននិយាយរឿងនោះទេ។



លោកស្រី ជឹម សំអឿន



# គង់ វណ្ណា

ហៅចៅគិត អាយុ ៥៣ឆ្នាំ សព្វថ្ងៃរស់នៅស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ធ្វើស្រែ មានប្រពន្ធ មានកូន៣នាក់ មានបងប្អូន១១នាក់ ស្រី៥ ប្រុស៦ នៅរស់ប្អូន ស្រី១ និងបងស្រី២នាក់ មុនរបបខ្មែរក្រហម ជាសិស្សលាសា និងចូលរួមក្នុងរណសិរ្សផ្នែកសិល្បៈ

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោក វណ្ណា រស់នៅស្រុកខាងលើដដែល គាត់មើលក្របី ធ្វើស្រែ និងបររទេះសេះដឹកសំភារៈសំរាប់ផ្ទះបាយ និងធ្លាប់ដឹករបស់មានតម្លៃដូចជា មាស ប្រាក់ ឬគ្រឿងទាំងនោះតាមការបញ្ជារបស់គេ។ នៅឆ្នាំ១៩៧៨ រដូវស្ទូងប្រហែលខែតុលា ពួកខ្មែរក្រហមបានសម្លាប់បងស្រីម្នាក់ និងបងប្រុសគាត់ម្នាក់។ មួយអាទិត្យក្រោយមកនៅម៉ោងប្រមាណ៧យប់ មានមនុស្សប្រុសម្នាក់មកហៅបងស្រីគាត់ម្នាក់ទៀតទៅប្រជុំ។ បងស្រីគាត់ក្រោយនេះឈ្មោះ គង់ សំអន អាយុ២៣ឆ្នាំ ជាប្រធានកងនារីឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល។ ដោយបារម្ភចំពោះបងស្រីគាត់ម្នាក់នេះទៀតគាត់ក៏សូមជូនបងស្រីទៅប្រជុំដែរ។ ពេលធ្វើដំណើរបានពាក់កណ្ដាលផ្លូវគាត់ជួបមនុស្សប្រុស២នាក់ទៀត ហើយគេបញ្ជាឱ្យគាត់ត្រឡប់មកផ្ទះវិញ តែគាត់បានលបទៅតាមផ្លូវវាងមួយទៀត។

គេបាននាំបងស្រីគាត់ទៅក្នុងបន្ទប់មួយខាងក្រោមកុដិក្នុងវត្តបឹងជរ៉ៃ។ នៅខាងក្រៅបន្ទប់មានមនុស្ស៣-៤នាក់ នៅខាងក្នុងវិញមានជនល្មើស៤នាក់ ក្មេងកំលោះ២នាក់ និងបុរសចំណាស់មានប្រពន្ធ២នាក់។ នៅក្នុងបន្ទប់ជនល្មើសម្នាក់បានគូសដែកកេះដុតបាច់ស្លឹកដូងចាស់ៗដើម្បីបំភ្លឺ។ គាត់ស្គាល់ច្បាស់ដោយជនល្មើសទាំងនោះរស់នៅក្នុងភូមិជាមួយគ្នា។ ជនល្មើសដែលមានវ័យចំណាស់ជាងគេបានឱ្យបងស្រីគាត់ដោះអាវ។ ពេលនោះបងស្រីគាត់ហាក់បីភាន់ភាំង ហើយមិនព្រមធ្វើតាមគេរួច " អាកំលោះម្នាក់ចាប់ហែកអាវ អាចាស់ម្នាក់ស្រាតខោបងស្រីខ្ញុំ " គាត់និយាយ។ ជនល្មើសកំលោះម្នាក់នោះរំលោភបងស្រីគាត់មុនគេ។ បន្ទាប់ពីរំលោភហើយ ជនល្មើសនោះបាននិយាយថាៈ " ង៉ែងនឹងប៉ុណ្ណឹងទេ តិចទៀត ស្ទួលដីហើយង៉ែង... "។ បន្ទាប់មកជនល្មើសទី២វ័យចំណាស់ចាប់ផ្ដើមរំលោភបន្ត។ គេបានរំលោភបងស្រីគាត់ទាំង៤នាក់។ គាត់លបមើលឃើញហេតុការណ៍ទាំងនោះពីខាងក្រៅបន្ទប់ នៅចំងាយប្រហែល៣-៤ម៉ែត្រពីកន្លែងគេរំលោភបងស្រីគាត់តាមបង្អួចម្ខាងដែលបាក់ស្លាបព្រិលមួយសន្លឹកព្រមទាំងអាចមើលឃើញដោយពន្លឺស្លឹកដូងឆេះសល់លើឥដ្ឋក្បែរនោះ។ ដោយពិបាកទ្រាំមើលនូវហេតុការណ៍នោះ និងខ្លាចគេដឹងផងគាត់ក៏ដើរចេញចំងាយ៣០ម៉ែត្រពីទីនោះដើម្បីចាំតាមដានបន្តទៀត។ ម៉ោងប្រហែល១០យប់ គាត់ឮសម្លេងបងស្រីគាត់ស្រែកខ្ញ័រក្នុងបន្ទប់ជាសំឡេងបែបត្រូវគេវាយធ្វើបាប។ ក្រោយមកគាត់ឮសម្លេងបើកទ្វារបន្ទប់នោះ គាត់កាន់តែឮសម្លេងបងស្រីគាត់ឈឺចាប់កាន់តែច្បាស់ និងជេរប្រទេចទៅលើពួកជនល្មើសផងដែរ។ គេបន្តវាយបងស្រីគាត់ទៀតរហូតស្ងាត់មាត់។ គាត់យល់ថាបងស្រីគាត់បានស្លាប់ហើយ។

ក្រោយការរំលោភបាន៣ថ្ងៃ គាត់លបទៅមើលកន្លែងគេរំលោភបងស្រីគាត់ម្ដងទៀតនៅពេលថ្ងៃ។ គាត់បានប្រទះឃើញគល់ឬស្សីមានប្រឡាក់ឈាម ខោក្នុង និងខ្សែកប្រាក់របស់បងស្រីគាត់ដាច់នៅទីនោះ។ សពរបស់បងស្រីគាត់ត្រូវគេកប់នៅឃើញដៃជើង ក្បែរគល់ខ្នុរមួយក្នុងវត្តចំងាយប្រហែល២០ម៉ែត្រ ពីកន្លែងរំលោភ។ ជនដៃដល់ទាំង៤នាក់ខាងលើ ៣នាក់នៅរស់ ហើយមាន២នាក់កំពុងរស់នៅក្នុងភូមិជាមួយគាត់សព្វថ្ងៃ។ ម្នាក់ទៀតធ្វើការជំគ្រាន់បើនៅក្នុងខេត្តព្រៃវែងនេះ។ គាត់ថាយើងមិនបាច់ដាក់ឈ្មោះគេទេ ប្រសិនគេបានអានរឿងនេះគេអាចដឹងថា តើគេពិតជាបានធ្វើអ្វីខ្លះហើយ។



លោក គង់ វណ្ណា

## អារម្មណ៍ និងការចងចាំ

គ្រាន់តែឃើញគេយកបងស្រីចូលក្នុងបន្ទប់ហោត្រៃក្នុងវត្តនោះ រួចបង្ខំឱ្យបងស្រីគាត់ដោះខោអាវ គាត់យល់ថាបងគាត់ពិតជាស្លាប់ម្នាក់ទៀតហើយ។ ភ្លាមនោះគាត់រន្ធត់ជាខ្លាំងបំរុងចូលទៅជួយបងគាត់ គាត់មិនខ្លាចស្លាប់ទេតែនឹកគិតទៅប្អូនៗ និងម្តាយចាស់ តើនឹងទៅជាយ៉ាងណាថ្ងៃក្រោយ។ គាត់មានការសោកស្តាយជាខ្លាំង។ ទី១ក្រោយរឿងនោះកើតឡើងភ្លាម គាត់បានប្រាប់ទៅម្តាយគាត់ ហើយម្តាយគាត់ស្លុតស្មារតីនិងធ្លាក់ខ្លួនឈឺរហូតស្លាប់ពេលក្រោយមក។ ទី២គាត់តូចចិត្ត ដោយមិនអាចធ្វើអ្វីកើតនៅពេលឃើញគេធ្វើបាបបងស្រីយ៉ាងដូច្នេះ។ រឿងនេះគាត់នឹកឃើញដល់វាសនាសង្សារគាត់ម្នាក់ ដែលគេប្រាប់គាត់ថា ត្រូវគេរំលោភយ៉ាងដូច្នោះដែរ។ គាត់គិតថាពួកវានោះ ឬរបបនោះវាសាហាវណាស់។

រឿងនេះគាត់មិនដែលនិយាយប្រាប់អ្នកណាទេក្រៅពីម្តាយគាត់ម្នាក់។ គាត់ថា: "ការតស៊ូដោយកំហឹង ឬការសងសឹក ជាការឥតប្រយោជន៍ តែបើធ្វើមិនដឹងមិនឮអ្វីសោះក៏មិនល្អ ហើយនាំអោយកាន់តែចុកចាប់តទៅទៀត..."។ គាត់បានទៅរកអង្គការសិទ្ធមនុស្សចំនួន២ដើម្បីនិយាយរឿងនោះ តែហាក់ដូចមិនមានចម្លើយពិតប្រាកដ។ តែពេលនេះគាត់គ្រាន់តែ និយាយតាមវិទ្យុតែម្តងគត់បំណងគាត់បានសំរេច។ ការសំរេចចិត្តនិយាយរឿងរបស់បងស្រីគាត់មិនជាការរីករាយប៉ុន្មានទេ តែបានជួយដល់ការចងចាំមួយអំពីជីវិតរបស់បងស្រីគាត់ម្នាក់ដែរ ហើយក៏ប្រាប់ដល់មនុស្សទូទៅ និងមនុស្សជំនាន់ក្រោយឱ្យបានដឹងថានៅរបបនោះឃោរឃៅបែបណា។ គាត់ក៏សំណូមពរប្រសិនជាអាចគួរជារូបភាពនៃអំពើឃោរឃៅនោះទុកក៏ល្អដែរព្រោះគាត់នៅចាំច្បាស់ណាស់។

# អិន ប៊ិច

អាយុ៧៥ឆ្នាំ នៅផ្ទះ រស់នៅស្រុកទ្រាំង ខេត្តតាកែវ មានកូន៥នាក់នៅរស់ស្រី១ ប្រុស១ មុនរបបខ្មែរក្រហម ធាក់ស៊ីក្លូ និងធ្វើទាហាន លន់ នល់ ត្រឹមឆ្នាំ១៩៧២ ត្រឡប់មកធ្វើស្រែវិញ

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម



លោក អិន ប៊ិច រស់នៅក្នុងស្រុកកំណើតខាងលើដដែល ធ្វើជាសេដ្ឋកិច្ច រកបន្លែផ្គត់ផ្គង់សហករណ៍ ធ្វើជាចុងភៅ និងជាប់ឃុំឃាំងជិត២ខែ រហូតថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩។ គាត់បានឃើញអំពើហិង្សាផ្លូវភេទចំនួន២ករណី។ ករណីទី១ នៅឆ្នាំ១៩៧៧ នារដូវប្រាំងមាននារីកងចល័តម្នាក់ (មិនស្គាល់អត្តសញ្ញាណ) អាយុប្រហែល១៨ឆ្នាំ សុំគេមកជួបឪពុកម្តាយនៅសហករណ៍នៅឃុំរនៀមនេះ។ តែអកុសលឪពុកម្តាយនារីនោះបានស្លាប់ចោលនាងអស់ហើយ។ ប្រហែលនារីនោះឃ្លានខ្លាំងបានទៅដកដំឡូងគេហូបរួចត្រូវគេចាប់បាន និងនាំទៅវត្តត្រពាំងធំ។ នៅទីនោះមានឈ្លប៣នាក់ ម្នាក់ឈ្មោះ ឆឹង ជាកូនប្រុសប្រធានឃុំ អាយុប្រហែល១២ឆ្នាំ។ ឈ្លប២នាក់ទៀតអាយុប្រហែល២០ឆ្នាំ តែគាត់មិនស្គាល់គេទេ។ ឈ្មោះឆឹងក្មេងជាងគេ តែមានអំណាចជាងគេ។ ឈ្លបទាំង៣នោះបាននាំនាងឡើងទៅលើកុដិមួយនៅម៉ោងប្រហែល៩ព្រឹក។ ដំបូងគេបានឱ្យនារីនោះដោះខោអាវចេញ តែនាងដោះត្រឹមតែខ្សៅអាវទេ។ ដោយគេបង្ខំខ្លាំងនាងក៏ព្រមដោះតាមបញ្ជាគេ។ បន្ទាប់មកឈ្មោះឆឹងបានឱ្យនាងអង្គុយចុះ ហើយឈ្ងោកមើលប្រដាប់ភេទនាង។ រួចឈ្មោះឆឹង បានបញ្ជាទៅឈ្លបម្នាក់ឱ្យរំលោភនាងឱ្យខ្លួនមើល។ ហើយឈ្មោះឆឹង ក៏បញ្ជាទៅឈ្លបម្នាក់ទៀតឱ្យរំលោភនាងនោះទៀត តែឈ្លបទី២ បានប្រកែកព្រោះខ្លាចមានទោសរឿងខុសសីលធម៌។ ឆឹងគំរាមដោយយារកាំភ្លើងរកវាយទៅឈ្លបទី២នោះព្រមទាំងពោលថា: "ខ្លាចអី បើអញនៅទីនេះហើយខ្លាចអីទៀត..." រួចឈ្លបទី២នោះក៏ព្រមរំលោភនាងនោះទៅ។



លោក អិន ប៉ិច







ក្រោយការំលោភហើយ ឈ្មោះឆឹងបានយកសំឡីគរុំលើកំណាត់ឫស្សីដាក់ប្រេងកាត រួចយកទៅដុតរោលលើកេ្តីភេទនាងនោះ ហើយសិកចូកទៅក្នុងប្រដាប់ភេទនាងតែម្តង។ បន្ទាប់មកគេបណ្តើរនាងទាំងខ្លួនអាក្រាតចុះមកក្រោម បានមួយកាំទើបដុំសំឡីជាមួយឫស្សីនោះរបូតជ្រុះ។ គេរុញនាងចូលទៅបន្ទប់ខាងក្រោមកុដិជាមួយអ្នកទោសផ្សេងទៀត ទើបបោះខោអាវឱ្យតាមក្រោយ។ គាត់ថាទាំងការគេរំលោភ និងដុតរោលប្រដាប់ភេទនាងមិនហ៊ានស្រែកយំខ្លាំងទេ។ គាត់ឃើញហេតុការណ៍ទាំងនោះដោយគាត់ត្រូវទៅជួបមេកងដើម្បីសុំលិខិតធ្វើដំណើរទៅរកបន្លែ។ ពេលទៅដល់ក៏ឃើញគេនាំនារីម្នាក់ហ្នឹងឡើងលើកុដិ។ គាត់ក៏ឡើងតាមក្រោយ ពេលទៅដល់ពួកឈ្លបបានដេញគាត់ចេញ គាត់ក៏ដើរឆ្លងតាមស្ពានមួយទៅកាន់សាលាឆាន់នៅក្បែរនោះនៅចំងាយប្រហែល៥ម៉ែត្រពីកន្លែងរំលោភ នៅលើរានហាលខាងក្រោយកុដិ ទើបគាត់អាចមើលឃើញហេតុការណ៍ទាំងអស់។ ចំពោះវាសនានារីនោះក្រោយមកយ៉ាងណាក៏គាត់មិនបានដឹងទេ។ រីឯឈ្លបឈ្មោះឆឹងវិញក៏បានឈឺស្លាប់ ហើយឪពុកគេជាប្រធានឃុំក៏ត្រូវគេសម្លាប់ក្នុងរឿងខុសសីលធម៌។ ចំណែកឈ្លប២នាក់ទៀតក៏ស្លាប់អស់ហើយដែរ។

ករណីទី២: កើតឡើងនៅឆ្នាំ១៩៧៨ នារដូវវស្សានៅក្នុងឃុំរនៀមដូចគ្នា។ នៅម៉ោងប្រហែល១០ព្រឹក ខណៈ គាត់ និងម្នាក់ទៀតឈ្មោះចនកំពុងរកកាប់ផ្លែត្នោតក្បែរព្រៃមួយ។ គាត់បានឃើញបុរស៣នាក់បណ្តើរស្ត្រីម្នាក់អាយុប្រហែល២៨ឆ្នាំ ជាស្ត្រីមេម៉ាយ នូវដៃកំពុងបកដំឡូងផង។ នារីនោះឈ្មោះប៉ាឡា រស់នៅក្នុងភូមិក្បែរគាត់ជាប្រជាជនថ្មី។ បុរសទាំង៣នាក់នោះជាអ្នកចាំចំការ ម្នាក់ជាប្រធានឈ្មោះហង ឈ្មោះពិន និងឈ្មោះខែមជាសមាជិក។ គាត់គិតថានារីនោះ ប្រហែលជាទៅដកដំឡូងគេហើយ ត្រូវគេចាប់យកមកទីនេះនឹងធ្វើអ្វីម្យ៉ាងលើរូបនាង។ ដូចគាត់គិតមែន! គេបាននាំនារីនោះមកកន្លែងគាត់កំពុងរកកាប់ផ្លែត្នោតនៅចំងាយប្រហែល២០ម៉ែត្រពីគាត់។ ពួកគេទាំង៣នាក់មិនដឹងថាគាត់នៅក្បែរនោះទេ។ គេបានឱ្យនារីនោះអង្គុយចុះហើយឱ្យដោះខោអាវ។ នាងធ្វើអ្វីៗទៅតាមគេបញ្ជាដោយមិនមានហ៊ានប្រកែកអ្វីឡើយ។ បុរសទី១ឈ្មោះហងបានចាប់ផ្តើមរំលោភមុនគេ។ រំលោភហើយគេយកខោអាវនារីនោះទៅជូតប្រដាប់ភេទគេ។ រួចបុរសទី២ឈ្មោះពិនក៏ចាប់ផ្តើមរំលោភបន្ត រួចយកខោអាវនារីនោះជូតប្រដាប់ភេទដូចគ្នាទៀត។ ចំពោះបុរសទី៣ឈ្មោះខែមក៏ធ្វើដូច្នោះដែរ។ គាត់មិនឮសម្លេងនារីនោះទេគ្រាន់តែឮសម្លេងជជែកគ្នារងំៗរបស់ពួកប្រុសៗ៣នាក់នោះប៉ុណ្ណោះ។



បន្ទាប់ពីរំលោភរួចហើយ គេចាប់ទាញដៃស្ត្រីនោះឱ្យងើបអង្គុយរួចគេក៏យកដំបងវាយនារីនោះភ្លូស១តែម្តង នៅពេលនេះក៏គាត់មិនឮសំឡេងអ្វីផ្សេងដែរ។ រួចគេបោះខោអាវនារីនោះទៅលើចុងឫស្សីហើយក៏ដើរទៅទិសខាងលិចនៅម៉ោងប្រហែល១២ថ្ងៃត្រង់។ គាត់ និងគ្នាគាត់ម្នាក់ទៀតក៏ធ្វើដំណើរចេញពីនោះមកភូមិវិញយ៉ាងលឿនដែរ។ ប្រហែលមួយអាទិត្យក្រោយមក គេបានចាប់ឈ្មោះហងជាអ្នករំលោភទី១ទៅគុកនៅជើងចាប។ ពីរ-បីថ្ងៃក្រោយ គេចាប់រូបគាត់ និងគេចាប់ឈ្មោះចន ដែលបានឃើញហេតុការណ៍នោះទៀត រួចទើបគេចាប់ឈ្មោះពិន និងខែមជាអ្នករំលោភទាំង២នាក់ទៅដាក់នៅគុកជើងចាបទាំងអស់គ្នា។ ចំពោះអ្នករំលោភទាំង៣នាក់នោះស្លាប់អស់ហើយ។ ឈ្មោះចនសព្វថ្ងៃនៅរស់ធ្វើទាហាននៅឯព្រំដែន។



## អារម្មណ៍ និងការចងចាំ

នឹកតែពុទ្ធោទេ គិតថាកូនគេកូនយើង មិនសមបើត្រូវគេធ្វើបាបយ៉ាងនេះសោះ។ គាត់ថារឿងនេះគាត់មិនដែលនិយាយទេ ថ្វីបើគ្នាស្លាប់ទៅហើយមិនគួរនិយាយរឿងរបស់គ្នាទៀតទេ។ គាត់សំរេចនិយាយរឿងនេះ គឺគាត់អាយុ៧៥ឆ្នាំហើយ បើគាត់មិននិយាយរឿងនោះប្រហែលមនុស្សជំនាន់ក្រោយមិនដឹងថាមានអ្វីខ្លះបានកើតឡើងនៅរបបនោះទេ។ គាត់គ្មានបំណងនិយាយអាក្រក់-ល្អពីអ្នកណាទេ គ្រាន់តែនិយាយតាមការពិតដែលគាត់បានដឹងប៉ុណ្ណោះសំរាប់មនុស្សជំនាន់ក្រោយ។

# មាស គឹម ឆន

ហៅគ្រូលាង អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មានមុខរបរជានាយកសាលាបឋមសិក្សាស្រះឃ្លាំង រៀបការលើកទី២ នៅឆ្នាំ១៩៧៩ មានកូន៥នាក់ ស្រី៣ប្រុស២ មុនរបបខ្មែរក្រហមគាត់បួស នៅវត្តឧណ្ណាលោមក្រុងភ្នំពេញរហូតដល់ឆ្នាំ១៩៧៥

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោក គ្រូលាង នៅស្រុកថ្មពួក ខេត្តបាត់ដំបង កាប់ដី ស្ទូង ធ្វើស្រែ ជីកប្រឡាយ និងធ្វើការគ្រប់បែបយ៉ាង។ នៅខែមិថុនាឆ្នាំ១៩៧៨ គាត់មានអាយុ២៦ឆ្នាំ ត្រូវរៀបការក្នុងចំណោម៥៦គូ។ មាននារីមេម៉ាយម្នាក់អាយុ២១ឆ្នាំ ស្នើគាត់រៀបការ។ ស្ត្រីនោះជាអ្នកសុំទៅប្រធានសហករណ៍ ហើយប្រធានកងបានប្រាប់គាត់អំពីរឿងនេះ។ គាត់មិនស្រឡាញ់ស្ត្រីនោះទេ តែមានគេចេះតែមកបញ្ចុះបញ្ចូល គាត់ក៏យល់ព្រមទៅ។ គាត់ថាស្ត្រីនោះក៏មិនស្រឡាញ់គាត់ពិតប្រាកដដែរតាមគាត់យល់ គឺស្ត្រីនោះមានមូលហេតុបីយ៉ាង។ ទី១ គឺកុំឱ្យគេតាមដាន ឬសង្ស័យមកលើស្ត្រីនោះបន្តទៀត ព្រោះប្តីមុនរបស់ស្ត្រីនោះត្រូវគេចោទថាក្បត់អង្គការ។ ទី២ ពេលដែលបានរៀបការហើយស្ត្រីនោះអាចបានមករស់នៅក្នុងភូមិវិញ និងបានជួបជុំម៉ែ-ឪ។ ទី៣ ឋានៈគ្រួសារស្ត្រីនោះជាអភិជនកាលពីជំនាន់មុន ជាអ្នកមាន រៀនសូត្រខ្ពង់ខ្ពស់ ដែលផ្ទុយពីរូបគាត់ និងគ្រួសារគាត់ទាំងអស់។ ចំពោះការរស់នៅរបស់គាត់វិញមើលពីខាងក្រៅទៅថាជាប្តីប្រពន្ធ តែតាមពិតមិនមែនទេ។ គាត់ថា ការរៀបការរបស់គាត់គង់ថ្ងៃណាមួយនឹងបែកគ្នាជាមិនខានព្រោះមានជំនឿរៀងៗខ្លួនថា មិនមែនជាប្តីប្រពន្ធពិតប្រាកដទៅអនាគតឡើយ។

ដូចការចិញ្ចឹមចិត្តរបស់គាត់មែន ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ នៅខែមេសា គាត់សំរេចចិត្តចាកចេញពីប្រពន្ធដែលរៀបការនៅរបបខ្មែរក្រហមនោះតែម្តង។ គាត់បានធ្វើដំណើរមករកបងស្រីគាត់នៅស្រុកកំណើតនៅខេត្តកំពង់ស្ពឺ ហើយបានជួបបងស្រីគាត់ដូចប្រាថ្នា។ ក្រោយមកបងស្រីគាត់ក៏រៀបចំផ្សំផ្គុំឱ្យគាត់មានគូស្រករថ្មី ហើយរស់នៅជាមួយគ្នាសុខសាន្តរហូតមកដល់សព្វថ្ងៃ។

## អារម្មណ៍ និងការចងចាំ

គាត់ថាការរៀបការពីលើកមុន និងលើកក្រោយនេះគឺខុសគ្នា។ គាត់គិតថាការរៀបការនៅរបបខ្មែរក្រហម គាត់មានការតូចចិត្តច្រើនយ៉ាង ដូចជាការរៀបការគ្មានការជ្រើសរើសរបស់ខ្លួនពិតប្រាកដ ប្រពន្ធដែលគាត់រៀបការជាមួយជាស្ត្រីមេម៉ាយ គាត់នៅកំលោះ ប្រពន្ធមានឋានៈខុសគ្នានឹងគាត់ និងគ្មានការស្រឡាញ់ពិតប្រាកដទាំងសងខាង។ ការរៀបការលើកក្រោយនេះគាត់មានការពេញចិត្តច្រើន ឋានៈក៏ប្រហាក់ប្រហែលគ្នា។ ម្យ៉ាងទៀតប្រពន្ធគាត់ជាកូនកំព្រាដូចគាត់ដែរ ហើយការរស់នៅជាមួយគ្នាមាននិស្ស័យជាប្តីប្រពន្ធលើសពីនេះការរៀបការរបស់គាត់ជាលើកទី២នេះ ក៏អាចលប់បំបាត់អារម្មណ៍អាក្រក់ៗពីមុនបានផងដែរ។ គាត់ធ្លាប់និយាយរឿងនេះដែរ តែមិនច្រើនដូចលើកនេះទេ។ គាត់និយាយរឿងនេះឡើងដើម្បីអោយមនុស្សទូទៅយល់ថា ការរៀបការជាប្តីប្រពន្ធមិនមែនចេះតែចាប់ភ្ជួលដូចគោក្របីទេ។ មនុស្សមានបេះដូង និងត្រូវគិតពីអនាគត បើពុំដូច្នោះទេវាអាចជួបនូវបញ្ហានានាជាច្រើន អំពើហិង្សា គ្មានសុភមង្គល និងការលែងលះគ្នាតែម្តង។



លោក មាស គឹម ឆន ហៅគ្រូលាង







# ឈាង កន

អាយុ៥៥ឆ្នាំ សព្វថ្ងៃរស់នៅស្រុកកោះកុង ខេត្តកោះកុង ជាស្ត្រីមេម៉ាយ នៅផ្ទះលក់ដូរបន្តិចបន្តួច និងមានកូនស្រីម្នាក់ មុនរបបខ្មែរក្រហមធ្វើស្រែ នៅស្រុកកំពង់ត្រាច ខេត្តកំពត

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រី កនរស់នៅតំណាក់ចង្កើរ ខេត្តកំពត ធ្វើស្រែ ជីកប្រឡាយ និងមើលក្មេង។ ខ្មែរក្រហមចាប់ប្តីអ្នកស្រីយកទៅសម្លាប់នៅឆ្នាំ១៩៧៥ ដោយចោទថាគិញ ខណៈគាត់កំពុងមានផ្ទៃពោះ២ខែ។ គាត់ជួបនូវអំពើហិង្សាផ្លូវភេទជាបន្តបន្ទាប់មកលើរូបគាត់ផ្ទាល់នាដើមខែមករាឆ្នាំ១៩៧៩។ នៅព្រឹកមួយក្នុងឆ្នាំ១៩៧៧ មេកងម្នាក់បានប្រាប់គាត់ថាមិនបាច់ទៅធ្វើការទេថ្ងៃហ្នឹង ហើយក៏មានឈ្លបម្នាក់មកប្រាប់គាត់ថា តាអេជាមេឃុំឱ្យគាត់ទៅជួប។ ពេលទៅដល់ តាអេប្រាប់ឱ្យគាត់ចូលទៅក្នុងបន្ទប់មួយជាកន្លែងតាអេធ្វើការ រួចឱ្យគាត់ដោះខ្សែអាវគាត់ចេញ ដោយខ្លាចគាត់ក៏ព្រមធ្វើតាម។ តាអេសួរគាត់ថា: "តើប្តីអ្នកឯងធ្វើគិញមែនទេ? ហើយ តើប្តីអ្នកឯងធ្លាប់ ធ្វើជា សេ អ៊ី អា មែនទេ?" គាត់ឆ្លើយថា: "មិនមែនទេអត់ទេ"។ ខណៈនោះមេភូមិព្រៃធំបាននាំនារីកងចល័តវ័យជំទង់កូនកាត់ចិនម្នាក់មកដល់។ គាត់ឮគេចោទនាងថាលួចអំពៅគេ ហើយគាត់មិនដែលស្គាល់នារីនោះទេ។ តាអេក៏ប្រាប់ឱ្យគាត់បិតខ្សែអាវហើយឱ្យគាត់ទៅកន្លែងវិញ។ ពេលគាត់ចេញមកក្រៅបន្ទប់គេនាំនារីនោះចូលទៅជួបតាអេ។ គាត់ឮនារីនោះស្រែកថា: "កុំធ្វើបាបខ្ញុំអី" ហើយឮគេប្រាប់នាងនោះថានៅឱ្យស្ងៀម។ ឮតែប៉ុណ្ណឹងគាត់ក៏ដើរចេញ ពីទីនោះយ៉ាងលឿនមកកន្លែងគាត់វិញ គាត់ក៏មិនដឹងថាមានរឿងអ្វីកើតឡើងចំពោះនារីនោះដែរ។

នៅប៉ុន្មានថ្ងៃជិតរំដោះពីរបបខ្មែរក្រហម គេដកគាត់ពីក្រុមនារីកងមេម៉ាយមកសហករណ៍កែបវិញ។ តែសហករណ៍កែបគេមិនទទួលគាត់ឱ្យនៅទីនោះទេ គេបានបញ្ជូនគាត់ទៅកាន់កន្លែងច្រូតស្រូវនៅអូក្រសារ។ គាត់ទៅដល់ទីនោះ ប្រហែលម៉ោង៦ល្ងាច ក៏នៅសំរាកជាមួយយាយចំណាស់ម្នាក់។ ពេលព្រលប់នោះមានឈ្លបអាយុប្រហែល១៥ឆ្នាំម្នាក់ មកប្រាប់គាត់ថា: បង(ប្រធានរបស់គេ)ឱ្យគាត់ទៅជួប។ គាត់ដើរទៅតាមគេក្នុងព្រៃមិនឆ្ងាយប៉ុន្មានពីកន្លែងពួកគាត់ស្នាក់នៅទេ។ ពេលទៅដល់ប្រធានឈ្លបនោះនិយាយថា :"ហ្នឹងជាប្រពន្ធគិញ?" ហើយគេចោទគាត់ថាទើបរត់ពីសហករណ៍ផ្សេងមក។ គាត់ប្រាប់ពួកគេថា គេចាត់ឱ្យគាត់មកទីនេះទេ។ គេថាគាត់មាត់រឹងហ៊ានតមាត់នឹងគេផង។ ភ្លាមនោះពួកគេចាប់ផ្តើមបៀតបៀនលើរាងកាយគាត់គ្រប់បែបយ៉ាង ខ្លះចាប់ដោះ ខ្លះចាប់ប្រស្រាតខោអាវគាត់។ ពេលនោះគាត់ខំប្រវាយប្រតប់ជាមួយគេ គេកាន់តែវាយទាត់ធាក់គាត់ថែមទៀត។ គាត់ថាពួកក្មេងៗ ជាអ្នកចាប់ដៃចាប់ជើងគាត់ឱ្យគ្នាគេរំលោភម្តងម្នាក់ៗជាបន្តបន្ទាប់ចំនួន៣នាក់។ គាត់ក៏ងងឹតមុខ និងលែងដឹងខ្លួន ហើយក៏មិនដឹងថាមានប៉ុន្មាននាក់ទៀតបានធ្វើអ្វីខ្លះមកលើរូបគាត់ដែរ។ ពេលគាត់ដឹងខ្លួនឡើងប្រហែលជិតភ្លឺទៅហើយ គាត់ខំគេចចេញពីទីនោះរកកន្លែងដេកលាក់ខ្លួនក្បែរភ្លឺស្រែរហូតដល់ភ្លឺ ក៏ធ្វើដំណើរទៅច្រូតស្រូវជាមួយនឹងគេឯងទៅ ហើយមិនហ៊ាននិយាយរឿងនោះប្រាប់គេទេ។

ចំពោះអ្នកប្រព្រឹត្តមកលើគាត់ទាំងនោះគាត់មិនស្គាល់ពួកគេទេ។ គាត់មិនអាចដឹងថាពួកគេនោះមានគ្នាពិតប្រាកដប៉ុន្មាននាក់ដែរព្រោះយប់ងងឹត។ គាត់ក៏មិនដឹងថាពួកគេទៅថ្ងៃក្រោយនោះមានវាសនាយ៉ាងណាដែរ។ គាត់គ្រាន់តែយល់ថា ពួកគេជាកងឈ្លបមានកាំភ្លើង ជាមនុស្សអាយុប្រហែល៣០ឆ្នាំមានមាឌធំៗ ជាអ្នករំលោភគាត់។



អ្នកស្រី លាង កន









ក្រោយពីហេតុការណ៍ខាងលើកើតឡើងប្រហែល២-៣ថ្ងៃ គេឱ្យពួកគាត់ត្រឡប់មកតំណាក់ចង្អើរវិញ។ រឿងរ៉ាវលើកទី២ បានកើតឡើងចំពោះអ្នកស្រីកនជាថ្មីនៅថ្ងៃ៦ មករា ឆ្នាំ១៩៧៩។ ពេលពួកគាត់មកដល់តំណាក់ចង្អើរក្បែរភ្នំព្រុះ នៅវេលាយប់ក៏នាំគ្នាសំរាកក្រោមដើមឈើ។ មានឈ្លបម្នាក់បានមកហៅគាត់ជាមួយនឹងស្ត្រី៣នាក់ទៀត គឺមាន យាយតាចៀន ម៉ែក្រហឹម និងស្ត្រីម្នាក់ទៀតទៅប្រជុំមួយភ្លែត។ ពួកគាត់ដើរបានបន្តិចអ្នកស្រីបានទាក់នឹងខ្សែដួលទៅនឹងដី។ ឈ្លបនៅក្បែរនោះបានបន្ទោសគាត់ថា ដើរមិនចេះមើល ហើយគេចាប់ផ្ដើមទាត់ធាក់មកលើគាត់រួចអូសគាត់យកទៅរំលោភក្នុងព្រៃតែម្ដង។ គេចាប់ហែកអាវ ប្រស្រាតខោគាត់ អ្នកខ្លះចាប់សង្កត់ដៃ ខ្លះជាន់ជើង។ ពេលគេរំលោភគាត់ មិនឮពួកគេនិយាយអ្វីទេ។ គាត់ក៏មិនហ៊ានមាត់ ឬប្រកាយប្រតប់នឹងគេដូចនៅភូមិអូក្រសារនោះឡើយ ព្រោះគាត់ខ្លាចគេវាយធ្វើបាបកាន់តែខ្លាំងថែមទៀត។ គាត់ដឹងត្រឹមគេរំលោភគាត់ចំនួន៣នាក់ គាត់ក៏លែងដឹងខ្លួនទៅ ហើយមិនដឹងថាមានអ្វីខ្លះកើតឡើងចំពោះគាត់ទេនៅពេលបន្ទាប់មកទៀត។



ពេលគាត់ដឹងខ្លួននៅម៉ោងប្រហែល៣ទៀបភ្លឺ គាត់មានការឈឺចុកចាប់ពេញខ្លួន។ ប្រដាប់ភេទគាត់មានឈាម និងរបួសដែលអាចបណ្តាលមកពីការយករបស់រឹងអ្វីម្យ៉ាងទៅវាយបន្ថែមទៀត។ គាត់ខំគេចមករកកន្លែងសំរាកវិញ។ ពួកឈ្លបទាំងនោះប្រហែលគិតថា គាត់បានស្លាប់ហើយ។ ប៉ុន្មានម៉ោងក្រោយមកពេលបាត់រូបគាត់ពីទីនោះ ពួកគេបារម្ភខ្លាចបែកការណ៍។ មានឈ្លបភូមិម្នាក់បានតាមរកគាត់យ៉ាងតក់ក្រហលនៅយប់នោះ។ គាត់បានយាយម្នាក់ដែលស្គាល់គ្នាហៅគាត់ឱ្យចូលសំរាកជាមួយ និងជួយលាក់រូបគាត់ក្នុងរម្មូរកន្ទេល។ ចំនួនឈ្លបទាំងអស់ប៉ុន្មានពិតប្រាកដគាត់មិនបានដឹងទេ។ គាត់ស្គាល់ឈ្លបភូមិម្នាក់ឈ្មោះផា ដែលបានតាមរកគាត់នៅយប់នោះ ហើយគេក៏នៅរស់ដល់សព្វថ្ងៃនេះ។ក្នុងចំណោមអ្នករំលោភគាត់ទាំង៣នាក់នោះ គាត់ស្គាល់ម្នាក់ដែរ គេឈ្មោះខុមជាប្រធានឈ្លប។ ពួកអ្នករំលោភគាត់ទាំងនោះគឺមានអាយុប្រហែល២៨-២៩ឆ្នាំ និងមានប្រពន្ធកូនរួចហើយ។ ចំពោះជនល្មើសទាំងនោះមានវាសនាទៅថ្ងៃក្រោយយ៉ាងណាក៏គាត់មិនដឹងដែរ។ ចំពោះស្ត្រី៣នាក់ដែលដើរទៅប្រជុំតាមក្រោយគាត់ គាត់មិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេទេ។



## អារម្មណ៍ និងការចងចាំ

ក្រោយថ្ងៃរំដោះខែមករាឆ្នាំ១៩៧៩ គាត់មានផ្ទៃពោះ ហើយកូននោះជាកូនប្រុសអាយុបាន៧ថ្ងៃក៏ស្លាប់ទៅ។ គាត់មានការខ្មាសគេក្នុងភូមិជាខ្លាំង និងត្រូវគេរើសអើងមិនសូវគេរាប់រក និងប្រឈមនឹងការនិន្ទាផ្សេងៗ។ គាត់បានព្យាយាមលោតទឹកសម្លាប់ខ្លួនតែមិនស្លាប់។ ពេលខ្លះគាត់ដើរចូលព្រៃជ្រៅក្នុងបំណងឱ្យសត្វស៊ី។ តែឪពុកម្តាយគាត់បានជួយលើកទឹកចិត្តគាត់ឱ្យបន្តរស់នៅតទៅទៀត។ ក្រោយមកគាត់បានមករស់នៅឆ្ងាយពីស្រុកកំណើត។

ស្ត្រី៣នាក់ដើរទៅប្រជុំជាមួយគាត់អាចដឹងរឿងនោះ។ គាត់មិនដែលនឹកចង់និយាយរឿងនោះប្រាប់អ្នកណាទេ គាត់ចង់លាក់រឿងនេះមួយជីវិតរបស់គាត់។ តែមានថ្ងៃមួយនោះពេលគាត់កំពុងមើលខ្សែភាពយន្តជាមួយអង្គការ ធី ភី អូ ឃើញគេចាប់ទាញសក់ធ្វើបាបលើមនុស្សម្នាក់គាត់ក៏ក្តុកក្តួលខ្លាំង ហើយក៏ធ្លាយរឿងនោះប្រាប់អ្នកជំនួយផ្លូវចិត្តស្ត្រីវ័យចំណាស់ម្នាក់របស់អង្គការនេះ។ អ្នកផ្លូវចិត្តរូបនោះជាអ្នកជួយឱ្យគាត់និយាយចេញមកបន្តិចម្តងៗ។ អ្នកផ្លូវចិត្តរូបនោះ បានលើកទឹកចិត្តគាត់ឱ្យនិយាយទៅកាន់មនុស្សណាដែលគួរទុកចិត្តដើម្បីបានធូរស្បើយអារម្មណ៍។ សព្វថ្ងៃនេះគាត់ក៏បានធូរស្រាលច្រើនដែរ។ គាត់ចង់ប្រាប់ថា មិនត្រូវលាក់ការពិតដូចគាត់កន្លងមកទេ តែផ្ទុយទៅវិញកាន់តែមានបញ្ហាខាងផ្លូវចិត្តខ្លាំងឡើង និងគ្មានអ្នកណាអាចជួយអ្វីយើងបានឡើយ។

# ណាំ ម៉ុន

អាយុ៥០ឆ្នាំ ជាស្ត្រីមេម៉ាយមានកូន៦នាក់ សព្វថ្ងៃធ្វើស្រែរស់នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម និងមានបងប្អូន៦នាក់ មុនរបបខ្មែរក្រហមរស់នៅជាមួយម្តាយនៅខេត្តកំពង់ចាម នៅឆ្នាំ១៩៧៣ដោយឪពុកគាត់មកបង្កប់ខ្លួននៅភ្នំពេញក្នុងចលនារបស់ខ្មែរក្រហម គាត់ក៏បានមករស់នៅភ្នំពេញជាមួយឪពុកម្តាយគាត់ដែរ

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម



លោកស្រី ណាំ ម៉ុន ពេលខ្មែរក្រហមកាន់អំណាច គាត់ និងក្រុមគ្រួសារមករស់នៅទីក្រុងភ្នំពេញរហូតឆ្នាំ១៩៧៩។ នៅចុងឆ្នាំ១៩៧៥ គាត់ជាអ្នកដើរចែកថ្នាំពេទ្យឱ្យអ្នកទោសនៅគុកទួលស្លែង។ ឪពុកគាត់ជាអ្នកកាន់ភ័ស្តុភា និងបងប្រុស២នាក់ជាអ្នកយាមគុកទួលស្លែង ហើយម្នាក់ទៀតយាមនៅព្រលានយន្តហោះពោធិ៍ចិនតុង។ នៅឆ្នាំ១៩៧៧ឪពុកគាត់ត្រូវគេចាប់ដាក់គុកនៅទួលស្លែង។ ប្រហែល១០ថ្ងៃក្រោយមក គេចាប់ម្តាយគាត់យកមកដាក់គុកទួលស្លែងទៀត។ នៅទីនោះគាត់បានជួបឪពុកគាត់តែម្តងគត់ ហើយឪពុកគាត់ប្រាប់គាត់ថា កុំឱ្យធ្វើជាស្គាល់គ្នាប្រយ័ត្នគេសម្លាប់ទាំងអស់។ ចាប់តាំងពីពេលនោះមកគាត់លែងបានឃើញឪពុកគាត់រហូត។ ក្រោយពីគេសម្លាប់ឪពុកម្តាយគាត់នៅឆ្នាំ១៩៧៧ បងប្រុសគាត់២នាក់ដែលយាមគុកនៅទួលស្លែងក៏ត្រូវគេសម្លាប់ដែរ។ មិនត្រឹមតែប៉ុណ្ណោះបងប្រុសគាត់ម្នាក់ផ្សេងទៀតដែលយាមនៅព្រលានយន្តហោះពោធិ៍ចិនតុង ក៏ត្រូវគេយកមកសម្លាប់នៅទួលស្លែងទៀត។



## លោកស្រី ណាំ ម៉ុន





នៅឆ្នាំ១៩៧៨ គេឈប់ឱ្យគាត់ដើរចែកថ្នាំដល់អ្នកទោស។ គេឱ្យគាត់ដាំបន្លែ បន្ទាប់មកគេក៏ចាប់គាត់ដាក់គុកនៅទីនោះ ហើយគាត់ត្រូវអ្នកយាមគុកម្នាក់ចាប់គាត់រំលោភ។ នៅម៉ោងប្រហែល៦ល្ងាចនៅបន្ទប់តូច២ជាន់ក្រោម ជនល្មើសម្នាក់បានចូលមកក្នុងបន្ទប់គាត់គេប្រាប់ឱ្យគាត់ដេកផ្ងាគេយកដែសង្កត់ស្មា និងដោះអាវគាត់ រួចគេចាប់ស្រាតខោគាត់ ទាំងជើងម្ខាងគាត់នៅជាប់ខ្នោះ ហើយគេខ្ទប់មាត់ និងប្រាប់មិនឱ្យគាត់ស្រែក។ ក្រោយការរំលោភហើយគេប្រាប់គាត់ឱ្យស្លៀកពាក់វិញ តែសំលៀកបំពាក់គាត់ត្រូវប្រឡាក់ដោយឈាមជាច្រើនថ្ងៃមិនបានផ្លាស់ប្តូរទេ។ ប្រហែល១៥ថ្ងៃក្រោយមក គេបញ្ជូនគាត់ទៅគុកព្រៃស ទើបគាត់មានខោអាវថ្មីប្តូរ។

ចំពោះជនល្មើសនោះ គាត់មិនស្គាល់ឈ្មោះគេទេ គ្រាន់តែធ្លាប់ឃើញគេធ្វើការនៅគុកទួលស្លែង គេមានអាយុប្រហែល១៧-១៨ឆ្នាំ។ តាមគាត់ដឹងជននេះមិនត្រឹមតែជាអ្នកយាមទេ តែជាមនុស្សជំនិតនឹងឌុចទៀតផង។ ចាប់តាំងពីពេលនោះមកគាត់មិនដែលឃើញជនល្មើសនោះទេ។ ពេលត្រូវឡើងធ្វើសក្ខីកម្មនៅសាលាក្តីខ្មែរក្រហមអំឡុងឆ្នាំ២០០៨កន្លងទៅ គាត់បានជួបជនល្មើសនោះសាជាថ្មី។ គាត់បានប្រាប់ទៅមេធាវីរបស់គាត់។ ពេលជួបជាមួយជនល្មើសផ្ទាល់ ជនល្មើសនោះឆ្លើយថាមិនចំណាំគាត់ទេ។ ហើយសព្វថ្ងៃនេះគាត់ក៏មិនដឹងថាគេរស់នៅទីណាហើយគេធ្វើអ្វីដែរ។





## អារម្មណ៍ និងការចងចាំ

គាត់ថាមិនគួរមានរឿងបែបនេះកើតឡើងចំពោះគាត់ទេ គាត់តែងមានអារម្មណ៍ភ័យខ្លាចចំពោះរឿងបែបនេះ កើតមានដល់កូនៗគាត់សព្វថ្ងៃ។ គាត់គិតថាប្រសិនបើមិនមានរឿងបែបនេះកើតមានចំពោះគាត់ គាត់ពិតជាមានអារម្មណ៍ស្រស់ថ្លាជាងនេះ។ គាត់នៅតែនឹកឃើញរឿងនោះជាប់រហូត។ ពេលគាត់ជួបមុខជនល្មើសនោះជាលើកដំបូងឡើងវិញនៅសាលាក្ដីខ្មែរក្រហមដោយចៃដន្យ គាត់ញ័រដៃញ័រជើង ហើយខឹងនឹងរូបគេនោះ។

គាត់មុនដំបូងមិនហ៊ាននិយាយរឿងនេះប្រាប់គេទេ។ តែក្រោយមកពេលនិយាយរឿងនេះក៏បានធូរស្រាលខ្លះៗ ដោយបានគេជួយដឹងឮឈឺឆ្អាល និងរាប់រកមិនដូចការគិតរបស់គាត់ពីមុនទេ។ ម្យ៉ាងទៀតគាត់ចាស់ហើយមិនចង់លាក់បាំងរឿងនេះទៀតទេ។ ពេលគាត់និយាយរឿងនេះគាត់មានសើចលាយឡំផង មានក្មេងខ្លះប្រហែលមិនជឿគាត់។ ដើម្បីចងចាំរឿងទាំងនេះមានតែចងក្រងជាឯកសារហើយជួយពន្យល់ប្រាប់មនុស្សជំនាន់ក្រោយៗទៀត។

# លី វិផ្ទុតា

សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ ជានាយិកាអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រីនិងជាសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រក្រុងភ្នំពេញ មានបងប្អូន១០នាក់ ឪពុកជាអតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅមុនរបបខ្មែរក្រហមគាត់ ជាសិស្សរៀននៅសាលាដេកាដក្រុងភ្នំពេញ

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រី វិផ្ទុតា និងគ្រួសារត្រូវជម្លៀសទៅខេត្តកំពង់ស្ពឺ។ នៅចុងឆ្នាំ១៩៧៥ ត្រូវគេជម្លៀសបន្តទៅកាន់ភ្នំស្រុក ក្នុងខេត្តបាត់ដំបង។ ឆ្នាំ១៩៧៧ រូបគាត់ បងស្រីគាត់ និងបងថ្លៃប្រុសគាត់ម្នាក់ទៀតត្រូវពួកខ្មែរក្រហម ចោទថា ជាក្រុមបញ្ញាវន្តត្រូវយកទៅសម្លាប់។ សំណាងគាត់ និងបងស្រីគាត់ត្រូវគេឱ្យត្រឡប់មកវិញ តែបងថ្លៃប្រុសគាត់បានបាត់ខ្លួនពីពេល នោះមក។ ក្រោយមកគាត់ត្រូវគេបំបែកពីគ្រួសារ ទៅធ្វើការក្នុងក្រុមកងចល័តនារីដែលគាត់មានវ័យក្មេងជាងគេបំផុត មានអាយុត្រឹម១២ឆ្នាំ ប៉ុណ្ណោះត្រូវធ្វើការងារធ្ងន់ៗ ដកស្ទូង ជីកប្រឡាយដូចនារីកងចល័តដទៃទៀតដែរ។

នៅពេលយប់គាត់ត្រូវគេចាត់ឱ្យយាមនៅកន្លែងក្រុមកងនារីដែរគាត់ស្នាក់នៅ។ រាល់វេនយាម គាត់តែងតែជួបនូវហេតុការណ៍ដែលគេ យកនារីទៅសម្លាប់។ គាត់ថាមាននារីប្រហែលជិត២០នាក់ ដែលត្រូវគេយកទៅសម្លាប់នៅពេលយប់ម្តងម្នាក់ៗ ដោយចោទថាខ្មាំង។ គាត់បានរៀបរាប់ពីករណីមួយដែលបានកើតឡើងចំពោះនារីម្នាក់ឈ្មោះថា អាយុប្រហែលជាង២០ឆ្នាំ ជាអតីតនិស្សិតនៅខេត្តបាត់ដំបង។ ប្តីនារីឈ្មោះថានោះ គេចោទថាក្បត់អង្គការ ហើយត្រូវបានគេសម្លាប់រួចហើយ។ រឿងរបស់នារីឈ្មោះថានោះ កើតឡើងនៅរដូវវស្សា នៅភូមិប៉ោយសំរោង ស្រុកថ្មគោល ក្នុងខេត្តបាត់ដំបង។ នៅយប់នោះវេនគាត់យាម គេបានចាប់នារីឈ្មោះថាមកលើផ្ទះឈើមួយ របស់កម្មាភិបាលកន្លែងពួកគេធ្វើការ ហើយគាត់នៅយាមខាងក្រោមផ្ទះ។ នៅលើផ្ទះនោះមានប្រធានឈ្លបម្នាក់ឈ្មោះមិត្តយូ មិត្តរាន់ និងកូនឈ្លបគេម្នាក់ ឬពីរទៀត។ គាត់ឮសំឡេងប្រទូស្តរាយរបស់នារីថាជាមួយនឹងឈ្លបទាំងនោះនៅលើផ្ទះ។ តែគាត់មិនឮច្បាស់ថា យ៉ាងម៉េចខ្លះទេ គាត់គ្រាន់តែឮនូវសំឡេងនារីនោះស្រែកយំជាច្រើនលើកច្រើនសា ស្ងាត់មួយស្របក់ហើយឮយំទៀតមានសភាពបែបនេះ រយៈពេលប្រហែល១-២ម៉ោងគាត់ក៏មិនដឹងថា គេធ្វើអ្វីខ្លះចំពោះនារីនោះដែរ។ ក្រោយមកគេបានចងនារីឈ្មោះថានោះ ហើយបណ្តើរ ចុះមកដាក់លើរ៉ឺម៉ករួចដឹកនាងចេញទៅ។ ពេលនោះរូបគាត់ក៏ត្រូវគេឱ្យទៅជាមួយនឹងពួកគេដែរ ដើម្បីឱ្យឃើញផ្ទាល់នូវការធ្វើទណ្ឌកម្ម ទាំងនោះ និងជាការព្រមានដល់គាត់ផងដែរបើតាមគាត់យល់។

មួយរយៈក្រោយមកគាត់ឮពួកគេនិយាយគ្នាថា:"...សប្បាយស៊ីណាស់...មិនអន់ទេមួយនេះ...ស៊ីអស់ហើយ..."។ ពាក្យទាំងនេះគេសំដៅ ទៅលើនារីទាំងឡាយដែលត្រូវបានគេយកទៅសម្លាប់រួចហើយ។ គាត់ក៏មិនសូវជាចាប់អារម្មណ៍នឹងពាក្យទាំងនោះប៉ុន្មានទេ ហើយក៏មិន យល់ន័យថារំលោភឬយ៉ាងណាដែរ ព្រោះគាត់នៅក្មេងពេក។ តែគាត់គ្រាន់តែយល់ថា គេនិយាយសំដៅទៅលើនារីដែលគេសម្លាប់ទាំង នោះតែប៉ុណ្ណោះ។ ចំពោះវាសនាជនល្មើសឈ្មោះមិត្តយូ និងមិត្តរាន់ ក្រោយមកគាត់ឮថាត្រូវគេយកទៅសម្លាប់ដែរ។ តែគាត់មិនដឹងថា ការសម្លាប់ដោយមូលហេតុអ្វីពិតប្រាកដទេ ព្រោះពួកខ្មែរក្រហមតែងតែសម្លាប់គ្នាឯងយ៉ាងដូចនេះ និងជាបន្តបន្ទាប់។



លោកស្រី លី វិជ្ជុតា

## អារម្មណ៍ និងការចងចាំ

ពេលនោះគាត់មិនសូវជាគិតអ្វីវែងឆ្ងាយប៉ុន្មានទេ ព្រោះគាត់នៅក្មេង គិតតែពីខំធ្វើការងារឱ្យសកម្មដើម្បីបានរស់ និងហូបចុក។ តែក្រោយៗមកពេលគាត់ចេះពិចារណាគាត់យល់ថា ពួកខ្មែរក្រហមនេះ គេបានទាញយកផលប្រយោជន៍ពីនារីភេទលើផ្នែកសម្ផស្សរាងកាយនេះឱ្យអស់សិន មុននឹងគេសម្លាប់ពួកនាងចោល។ រឿងទាក់ទងនឹងហិង្សាខាងផ្លូវភេទក្នុងរបបខ្មែរក្រហមនេះគាត់មិនសូវបាននិយាយទេ គាត់ច្រើនបាននិយាយទៅកាន់មិត្តភ័ក្ដជាជនបរទេសមួយចំនួនប៉ុណ្ណោះ តែគាត់ឧស្សាហ៍និយាយរឿងទាក់ទងនឹងការធ្វើទណ្ឌកម្មទូទៅ និងការកាប់សម្លាប់ព្រោះគាត់បានឃើញវាផ្ទាល់ភ្នែក ហើយវាធ្វើឱ្យប៉ះពាល់អារម្មណ៍គាត់ខ្លាំង។ ពេលគាត់និយាយរឿងទាំងនោះចេញម្ដងៗ គាត់តែងទប់ទឹកភ្នែកមិនបាន តែសព្វថ្ងៃគ្រាន់បើហើយ ចេះទប់អារម្មណ៍បានដោយការឧស្សាហ៍និយាយរឿងទាំងនោះចេញមក។ ដើម្បីការចងចាំត្រូវតែចងក្រង និងឧស្សាហ៍រំលឹកដល់មនុស្សជំនាន់ក្រោយ។

# មា ទីកាស

អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅស្រុកកំពង់បាយ ខេត្តកំពត នៅជាមួយចៅ
ជនជាតិខ្មែរ-អ៊ីស្លាម មានកូន៩នាក់ នៅរស់២នាក់ ស្រី១ ប្រុស១

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

**លោកយាយ** ទីកាស បានរស់នៅតាកែនកោះស្លា ខេត្តកំពត គេឱ្យកាប់ព្រៃ ធ្វើចំការ និងធ្វើស្រែ។ ប្ដីគាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ រូបគាត់ផ្ទាល់ត្រូវឈ្លបវាយធ្វើបាបកូនប្រុសគាត់ម្នាក់ដែលនៅរស់មកដល់សព្វថ្ងៃត្រូវគេយកទៅកប់ទាំងរស់ ចំពោះកូនៗគាត់ដទៃទៀតត្រូវស្លាប់ជាបន្តបន្ទាប់ និងក្មួយស្រីគាត់ម្នាក់ត្រូវមេកងហៅទៅរំលោភ។ គាត់បាននិយាយថាក្មួយស្រីគាត់ម្នាក់នោះឈ្មោះសាស ជាខ្មែរ-អ៊ីស្លាមអាយុប្រហែលជាង២០ឆ្នាំ ជាស្ត្រីមេម៉ាយ ត្រូវមេកងរបស់នាងរំលោភនៅឆ្នាំ១៩៧៨។ ក្មួយស្រីគាត់បានប្រាប់គាត់ថាមេកងរបស់នាងចេះតែមកទាក់ទងនាង។ ក្រោយមកមានថ្ងៃមួយនៅម៉ោងប្រហែល៩ល្ងាច បន្ទាប់ពីសំរាកពីការងារ មេកងរូបនោះបានប្រាប់ឱ្យក្មួយស្រីគាត់ត្រូវតែទៅជួបរូបគេនៅកន្លែងមួយឈ្មោះព្រៃទឹងនៅចំងាយប្រហែលជាងមួយគីឡូម៉ែត្រពីសហករណ៍ដែលក្មួយស្រីគាត់រស់នៅ។ ដោយខ្លាចព្រោះគេជាមេកង នាងក៏ទៅជួប ហើយនាងក៏ត្រូវមេកងរំលោភពេលនោះឯង។ គាត់ថាមិនបានឃើញផ្ទាល់ភ្នែកទេ តែគាត់យល់ថាក្មួយគាត់មិនមែនសុខៗយករឿងអាស្រូវនោះមកប្រាប់គាត់ទេ ហើយបើរឿងនោះជាការយល់ព្រមសុខសប្បាយប្រហែលក្មួយគាត់មិនយំខ្សឹកខ្សួលប្រាប់គាត់ដែរ។ គាត់យល់ថាក្មួយគាត់មានការលំបាកជាខ្លាំងព្រោះក្មួយស្រីគាត់ប្រាប់គាត់ថា: "បើមានកន្លែងណារត់បាន ខ្ញុំនឹងរត់ទៅឱ្យឆ្ងាយហើយ។ ព្រមជាមួយគេក៏ស្លាប់មិនព្រមក៏ស្លាប់"។ គាត់មិនបានសួរដេញដោលលំអិតទេគាត់ត្រឹមតែប្រាប់ថាត្រូវចេះធ្វើយ៉ាងណាឱ្យបានសុខ ព្រោះបើគេដឹងគេនឹងយកទៅសម្លាប់ហើយ។ គាត់ និងក្មួយគាត់មិនហ៊ានមាត់ ឬរាយការណ៍ប្រាប់អ្នកណាផ្សេងទៀតទេ។ ក្មួយស្រីគាត់បានរស់រួចខ្លួនមករហូតក្រោយឆ្នាំ១៩៧៩ ទើបស្លាប់ដោយជំងឺ។ ចំពោះមេកងជាអ្នករំលោភក្មួយស្រីគាត់នោះវិញ គេមានឈ្មោះម៉ុកមានប្រពន្ធនិងកូនហើយ។ ក្រោយឆ្នាំ១៩៧៩ជនល្មើសរូបនេះក៏ត្រូវគេបាញ់ស្លាប់ដែរ។

## អារម្មណ៍ និងការចងចាំ

គាត់មានការឈឺចាប់ជាខ្លាំងដោយគេធ្វើបាបមកលើខ្លួនហើយ ខ្លួនមិនមានសិទ្ធិតវ៉ា ឬហាស្ដីអំពីរឿងនេះបាន មានតែការស៊ូទ្រាំទៅតាមកម្មនោះតែប៉ុណ្ណោះ។ គាត់មានចម្ងល់ថា ពួកខ្មែរក្រហមហាមប្រាមការខុសសីលធម៌ ហើយជាអ្នកបង្កើតច្បាប់ តែខ្លួនឯងជាអ្នកធ្វើខុសនឹងច្បាប់នោះព្រមទាំងមិនមានអ្នកណាធ្វើអ្វីគេបានទៀតផង។ គាត់យល់ថា បើពេលនោះមានច្បាប់ត្រឹមត្រូវគាត់នឹងប្ដឹងឱ្យគេចាប់ជនល្មើសនោះដាក់គុកតែម្ដង។ គាត់មិនដែលនិយាយរឿងនេះប្រាប់អ្នកណាទេក្រៅពីមេធាវីរបស់គាត់។ ហេតុដែលនាំឱ្យគាត់និយាយរឿងនោះចេញមកនៅឱកាសដែលពួកគាត់ជួបជុំគ្នាមួយជាមួយអ្នកដាក់ពាក្យបណ្ដឹងទៅសាលាក្ដីខ្មែរក្រហម ហើយគេបានប្រកាសថា បើបងប្អូនណាមានបញ្ហាអ្វីសូមនិយាយចេញមក។ គាត់មានការឈឺចាប់ច្រើនយ៉ាងក្នុងរបបខ្មែរក្រហម ដូចការរៀបរាប់ខាងលើ។ ដូច្នេះទើបគាត់និយាយរឿងនោះចេញមកដោយអាណិតក្មួយខ្លាំងពេកដើម្បីឱ្យតុលាការខ្មែរក្រហមនេះជួយរកយុត្តិធម៌ឬដឹងឮការពិតពីរឿងនេះផងដែរ។ ក្រៅពីនេះគាត់ក៏ចង់ឱ្យគេឯងដឹងថានៅរបបខ្មែរក្រហមនោះវាឃោរឃៅខ្លាំងណាស់។



## លោកយាយ មា ទីកាស







# ស៊ឹម សេដ្ឋា

អាយុ៤៩ឆ្នាំ សព្វថ្ងៃរស់នៅ ស្រុកស្វាយរៀង ខេត្តស្វាយរៀង មានកូន៣នាក់ ស្រី២ ប្រុស១ ធ្វើស្រែ និង ជួយលក់ដូរប្រពន្ធ មុនរបបខ្មែរក្រហម ជាសិស្សរៀននៅស្រុកស្វាយរៀង ខេត្តស្វាយរៀង

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោក សេដ្ឋា រស់នៅស្រុក និងខេត្តដដែល គេឱ្យជីកព្រែក វែកដី ធ្វើស្រែ និងធ្វើជីលេខ១ពីលាមកមនុស្ស លាយជាមួយដីដំបូករួចវែកដាក់ស្រែ។ នៅឆ្នាំ១៩៧៦ មានពេទ្យស្រី៧៤-៥នាក់ ឈ្មោះសៀត ឈ្មោះរ៉ន និងឈ្មោះហឿន ជាដើមតែងតែហៅឱ្យគាត់ធ្វើសសៃឱ្យពួកគេ។ ពេទ្យស្រី៧ទាំងនោះមានអាយុជាង២០ឆ្នាំ គាត់មានអាយុប្រហែល១៤ឆ្នាំប៉ុណ្ណោះ។ ពួកពេទ្យទាំងនោះស្នាក់នៅផ្ទះមួយនៅជិតកន្លែងគាត់រស់នៅប្រហែល១០០ម៉ែត្រពីគ្នា។ គាត់ត្រូវពេទ្យទាំងនោះហៅឱ្យធ្វើសសៃសំរាប់ពួកគេរាល់៧យប់។ មួយយប់៧គាត់ត្រូវធ្វើសរសៃឱ្យពេទ្យស្រីពី២-៣នាក់ ហើយក្នុងម្នាក់៧មានរយៈពេលប្រហែល១ម៉ោង។ ចំពោះពេទ្យខ្លះធ្វើរហូតដល់គេប្រាប់ថាបានហើយក៏មាន។ ពេលធ្វើសសៃជាទូទៅគេដោះអាវទុកតែអាវក្នុង(អាវទ្រនាប់)ទេ។ គាត់ត្រូវគេឱ្យច្របាច់ដៃ ជើង និងខ្លួនប្រាណគេ ឬប្រាប់ឱ្យចាប់ និងច្របាច់ត្រង់នេះត្រង់នោះតាមតែចិត្តគេ។ សួរថា តើពេទ្យទាំងនោះមានបំណងខាងផ្លូវភេទដែរទេ? តាមគាត់យល់ពេទ្យទាំងនោះខ្លះអាចមានបំណងលើសពីការធ្វើសសៃនោះទៀត ហើយហាក់បីដូចជាបើកដៃអោយគាត់ធ្វើអ្វីម៉្យាង។ តែដោយគាត់នៅក្មេងហើយខ្លាចមិនហ៊ានធ្វើអ្វីលើសពីនោះឡើយទោះពេលខ្លះគាត់យល់ពីបំណងមួយចំនួនរបស់គេក៏គាត់ធ្វើជាមិនយល់ដែរ។ ចំណុចខ្លះគាត់យល់ថាជារឿងមិនសមរម្យសោះដូចជា ឱ្យគាត់ដោះអាវឱ្យ ទុកតែអាវទ្រនាបជាដើម ហើយពេលខ្លះពេទ្យនោះហាក់មានអារម្មណ៍ពុះកញ្ជ្រោលប្លែក៧ទៀតផង។

មានពេទ្យម្នាក់ឈ្មោះសៀត ពេលខ្លះសុំធ្វើសសៃឱ្យរូបគាត់វិញម្តងតែដូចជាជន្លជន្លេញតែប៉ុណ្ណោះ ហើយពេទ្យរូបនោះលូកដៃចូលក្នុងអាវ ឬខោគាត់រួចច្របាច់ក្បែរ៧ប្រដាប់ភេទគាត់តែម្តង។ ជាមួយពេទ្យម្នាក់នេះពេលខ្លះគាត់ត្រូវគេឃាត់ឱ្យនៅជាមួយពី២០-៣០នាទីទៀត ដេកកំដរគេ គេដេកកើយភ្លៅលេងមុននឹងបានចាកចេញមកវិញ។ ការធ្វើសសៃនោះ គាត់ក៏បានរបស់ខ្លះ៧ហូបដែរដូចជា ដំឡូង ឬនំចំណីផ្សេង៧។ មួយឆ្នាំក្រោយមកគាត់ត្រូវគេបញ្ជូនឱ្យទៅវែកដីវិញ។ ចំពោះនារីពេទ្យទាំងនោះគាត់ក៏មិនដឹងយ៉ាងណាដែរ តែមាននារីពេទ្យម្នាក់ឈ្មោះសៀតបានមករកគាត់នៅឆ្នាំ១៩៨០ នៅឃុំឫស្សីជួរ ហើយបានសុំគាត់រៀបការ។ គាត់នៅក្មេងអាយុប្រហែល១៦-១៧ឆ្នាំ គាត់មិនមានបំណងរៀបការអ្វីទេ។

## អារម្មណ៍ និងការចងចាំ

គាត់មានការតូចចិត្ត ព្រោះបន្ទាប់ពីធ្វើការហត់នឿយហើយហូបចុកមិនឆ្អែតផង ត្រូវគេហៅមកធ្វើសសៃអោយគេពី២-៣នាក់ទៀតក្នុងមួយយប់៧មិនបានសំរាក ហើយមិនដែលហ៊ានប្រកែកម្តងណាទេ។ ចំពោះអារម្មណ៍ខាងផ្លូវភេទនោះគ្មានទេ ធ្វើអ្វី៧ទាំងការខ្លាចទាំងអស់។ ឥឡូវមានអារម្មណ៍ធូរស្រាលហើយ ពីមុនមកគាត់មិនដែលនិយាយរឿងនេះប្រាប់អ្នកណាទេ។ ការនិយាយពេលនេះគឺចង់ប្រាប់ពីការពិតមួយសំរាប់មនុស្សជំនាន់ក្រោយបានដឹង ដែលយើងជាមនុស្សប្រុសក៏មានការលំបាកខាងផ្លូវចិត្ត និងផ្លូវកាយដែរ។



លោក ស៊ឹម សេដ្ឋា







# នេត សារឿន

អាយុ៥៥ឆ្នាំ មានមុខរបរធ្វើស្រែ បច្ចុប្បន្នរស់នៅ ស្រុកស្វាយទៀប ខេត្តស្វាយរៀងមានកូន៣នាក់

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម



លោកស្រី សារឿន រស់នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ជានារីកងចល័ត ធ្វើស្រែ រែកដី ជីកប្រឡាយ។ នៅចុងឆ្នាំ១៩៧៨ រដូវច្រូតរួចគាត់ត្រូវគេជម្លៀសទៅខេត្តពោធិ៍សាត់។ គាត់គឺជាជនរងគ្រោះម្នាក់ដែលនៅរស់ក្នុងចំណោមនារី៣០នាក់ដែលពួកខ្មែរក្រហមយកទៅសម្លាប់ និងរំលោភមុនសម្លាប់។ រឿងនោះបានកើតឡើងនៅសហករណ៍ព្រែកជីកក្នុងខេត្តពោធិ៍សាត់។ នៅម៉ោងប្រហែល៦ល្ងាច ពេលពួកគាត់សំរាកពីរែកដី ពួកឈ្លបខ្មែរក្រហមបានជ្រើសរើសនារីមាឌមាំៗចំនួន៣០នាក់ គេប្រាប់ថាត្រូវទៅរែកអំបិល។ ពួកឈ្លបខ្មែរក្រហមមានគ្នាប្រហែល១០នាក់បាននាំពួកគាត់ទៅកាន់ព្រៃមួយ។ ដើរជិតដល់ព្រៃនោះពួកឈ្លបបានឱ្យពួកគាត់អង្គុយចុះ ហើយចាប់ចងពួកគាត់តែម្តង។ ពេលចងហើយគេបណ្តើរពួកគាត់ចូលទៅក្នុងព្រៃ។ នៅតាមផ្លូវមានអ្នកខ្លះយល់ថាគេយកទៅសម្លាប់ក៏ក្រាញមិនទៅតាមគេទេតែត្រូវគេវាយ។

ទៅដល់កន្លែងសម្លាប់ក្នុងព្រៃ គេចាប់ផ្តើមរំលោភ និងវាយសម្លាប់នារីទាំងនោះនឹងពូថៅ រួចគេអាករជាចុងក្រោយ។ នារីស្អាតៗទាំងអស់ត្រូវពួកគេរំលោភស្រេចតែចិត្ត។ នារីខ្លះត្រូវគេរំលោភរហូត៣-៤នាក់ទើបបានគេសម្លាប់។ គាត់បានឃើញហេតុការណ៍ទាំងអស់នោះច្បាស់ព្រោះជាថ្ងៃពេញបូរមី។ គេចាប់ផ្តើមសម្លាប់ និងរំលោភនារីទាំងនោះតាំងពីខែរះពេលព្រលប់ រហូតដល់ខែត្រង់ជិតពាក់កណ្តាលយប់ទើបដល់រូបគាត់។ គាត់គឺជាមនុស្សចុងក្រោយគេបង្អស់ដែលបានឈរចាំវេនរបស់ខ្លួនរហូតស្ពឹកពេញខ្លួនដោយមិនដឹងថានឹងត្រូវធ្វើយ៉ាងដូចម្តេច។



លោកស្រី នេត សារឿន









គាត់ត្រូវគេរំលោភចំនួន២នាក់ទាំងដៃជាប់ចំណង។ ក្រោយមកគាត់មិនដឹងថាគេធ្វើអ្វីមកលើគាត់ទៀតទេ។ ពេលគាត់ដឹងខ្លួនវិញវេលាជិតភ្លឺគាត់គ្មានខោអាវនៅជាប់នឹងខ្លួនទេមានឈាមពេញទាំងខ្លួន ដោយជនល្មើសកាប់គាត់ចំនួនពាកន្លែងត្រង់ក្បាលនឹងពូថៅ។ គាត់ខំប្រវេប្រវារកសម្លៀកបំពាក់ក្បែរសាកសពទាំងនោះដើម្បីគ្របខ្លួនគាត់។ គាត់បានឃើញសាកសពនៅជុំវិញខ្លួនគាត់ ហើយខំសម្លឹងរកមើលមួយស្របក់ក្រែងមានអ្នកនៅមានជីវិតដើម្បីបានជាគ្នា តែមិនមានឃើញឡើយ។ គាត់ខំដើរមករកភូមិវិញដោយមិនប្រាកដអំពីទិសដៅប៉ុន្មានទេ គាត់ដើរទៅតាមស្នូរមាន់រងាវ។ ពេលគាត់ដើរមកដល់ផ្ទះម្ដាយគាត់ តែម្ដាយគាត់មិនឱ្យគាត់ស្នាក់នៅទេព្រោះយល់ថា មិនយូរមិនឆាប់ពួកឃាតករនឹងដឹងរួចមកយកគាត់ទៅសម្លាប់ទៀតនឹងអាចយកមួយគ្រួសារ ឬអ្នកពាក់ព័ន្ធតែម្ដង។ ម្ដាយគាត់ប្រាប់ឱ្យគាត់រត់គាត់ក៏ចេះតែបន្តដំណើរដោយគ្មានទិសដៅ។ ពេលទៅដល់ភូមិ១មានគេជួយព្យាបាលរបួសគាត់។ ប្រហែល១៥ថ្ងៃក្រោយមកកងទ័ពវៀតណាមចូលមកដល់។

ចំពោះជនល្មើសទាំងនោះគាត់មិនស្គាល់គេទេ ព្រោះគាត់គឺជាប្រជាជនថ្មី។ ពួកជនល្មើសមានវ័យក្មេងៗ អាយុប្រហែល១៨-១៩ឆ្នាំ ភាគច្រើនគឺឈ្លបនៅទីនោះ។ មកដល់សព្វថ្ងៃនេះគាត់ក៏មិនដឹងថាពួកគេទាំងនោះរស់នៅទីណា ហើយមានវាសនាយ៉ាងណានោះទេ។

## អារម្មណ៍ និងការចងចាំ

ទារុណ្ឌកម្មមកលើរូបគាត់ធ្ងន់ធ្ងរដែលពិបាកទ្រាំណាស់។ តែចាត់ទុកថាជាសំណាងដ៏ធំមួយដែលបាននៅរស់មកដល់សព្វថ្ងៃនេះ។ ឥឡូវគាត់អាចទប់ចិត្តបានច្រើន កាលពីដើមឡើយរាល់ពេលថ្ងៃពេញបូរមីគាត់ដូចជាមានអារម្មណ៍នៅមិនសុខសោះតែងតែនឹកឃើញរឿងទាំងនោះ។ មានពេលខ្លះគាត់ដើរទៅតាមផ្ទះគេនៅក្នុងភូមិ ឬក៏ដើរនៅក្នុងផ្ទះរបស់គាត់។ ដោយមានអង្គការ ធី ភី អូ ជាអ្នកជួយខាងផ្លូវចិត្តគាត់ គាត់ក៏មានការធូរស្បើយច្រើន។ គាត់ធ្លាប់និយាយរឿងទាំងនោះប្រាប់គេដែរ ការដែលបាននិយាយចេញមកនេះគាត់ក៏កាន់តែធូរចិត្តទៀតដែរ។ ដើម្បីជាការចងចាំគាត់ពេញចិត្ត និងនិយាយរឿងទាំងនោះបើមានអ្នកណាគេចង់ដឹងពិតប្រាកដ។ ការនិយាយរបស់គាត់មកនេះគឺដើម្បីឱ្យក្មេងៗជំនាន់ក្រោយបានដឹងពីរឿងទាំងនោះ។



# សាត ភាព

អាយុ៥៤ឆ្នាំ ពោះម៉ាយ មានកូន៥នាក់ ប្រុស៤ ស្រី១ ធ្វើស្រែ សព្វថ្ងៃរស់នៅ ស្រុកបាធាយ ខេត្តកំពង់ចាម គាត់ចូលក្នុងចលនាតស៊ូប្រឆាំងលន់ ណុល និងពិការដៃម្ខាងនៅឆ្នាំ១៩៧៥

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោក ភាព នៅស្រុកបាធាយ ខេត្តកំពង់ចាម ធ្វើស្រែ គ្រប់គ្រងអ្នកពិការ និងធ្វើការផ្នែកពាណិជ្ជកម្មតំបន់។ គាត់បានប្រទះនូវរឿងហិង្សាផ្លូវភេទដូចតទៅ។ រឿងទី១នោះ កើតឡើងនៅឆ្នាំ១៩៧៧ រដូវប្រាំងគេបានប្រមូលប្រជាជនមកពីតាមភូមិប្រមាណ៣០០គ្រួសារ មកដាក់នៅវត្តមួយហៅថាវត្តតាមាសក្នុងស្រុកជើងព្រៃ។ នៅម៉ោងប្រហែល៧យប់ខែភ្លឺ គាត់និងក្មេងម្នាក់ដើររកគោ។ មកដល់ក្បែរព្រៃមួយមិនឆ្ងាយពីវត្តនោះ គាត់បានឮសំឡេងស្ត្រីស្រែកយំ និងឮពាក្យថា:"សូមកុំធ្វើបាបខ្ញុំ..."។ នៅចំងាយប្រហែល២០ម៉ែត្រ គាត់ឃើញមនុស្សប្រុស៤នាក់ និងស្ត្រីតែម្នាក់តាមប្រលោះគុម្ពឫស្សី។ ស្ត្រីនោះអាយុប្រហែលជាង២០ឆ្នាំ ។ អាចជាស្ត្រីដែលគេយកពីវត្តនោះមកព្រោះគ្មានភូមិនៅជិតនោះទេ។ គាត់មិនស្គាល់មនុស្សប្រុសទាំង៤នាក់នោះទេ គ្រាន់តែដឹងថាពួកគេជាយោធាព្រោះមានកាំភ្លើង។ គាត់មិនហ៊ាននៅតាមដានរឿងហេតុនោះតទៅទៀតឡើយ។

ពេលព្រឹកឡើងគាត់ធ្វើដំណើរទៅទីនោះម្តងទៀត គាត់ប្រទះឃើញខ្សែវអាវដាច់នៅទីនោះចំនួន២ មានឈាមប្រឡាក់នៅជាប់នឹងស្មៅមានស្នាមស្មៅទូកទីប្រហែល២ម៉ែត្របួនជ្រុង និងមិនឃើញមានសាកសពនៅទីនោះទេ។ គាត់យល់ថាជាការរំលោភផ្លូវភេទតែម្តង។ ទាំងនារីរងគ្រោះ និងជនល្មើសគាត់មិនដឹងថាពួកគេមានវាសនាយ៉ាងណាទេ។

រឿងទី២ កើតឡើងនៅក្បែរផ្លូវជាតិលេខ៦ចំងាយប្រហែល៣គីឡូម៉ែត្រពីស្គន់មកភ្នំពេញ។ នៅឆ្នាំ១៩៧៧ មិត្តជិតស្និទ្ធគាត់ម្នាក់ឈ្មោះយុទ្ធត្រូវគេចាប់យកទៅសម្លាប់។ ៤ថ្ងៃក្រោយមកប្រពន្ធរបស់យុទ្ធត្រូវគេចាប់ដែរ។ នាងឈ្មោះសេងអាយុប្រហែលជាង២០ឆ្នាំ មានកូនតូចម្នាក់អាយុប្រហែល៤ឆ្នាំ ហើយនាងក៏កំពុងមានផ្ទៃពោះទៀតផង។

នៅរសៀលនោះពេលគាត់ធ្វើដំណើរដោយរថយន្តត្រឡប់ពីដីកស្រូវនៅស្រុកបាធាយវិញ មានរថយន្តមួយគ្រឿងទៀតបានឈប់នៅក្បែរផ្លូវនោះដែរ។ មានមនុស្ស២នាក់កាន់កាំភ្លើងបានហៅរថយន្តគាត់ឱ្យឈប់សុំជួយបូមកង់រថយន្តរបស់គេ។ ពេលរថយន្តគាត់ឈប់គាត់ក្រឡេកទៅម្ខាងផ្លូវចំងាយប្រហែល៣០ម៉ែត្រពីរថយន្តគាត់ គាត់ឃើញមនុស្សប្រុស៤នាក់ទៀត កំពុងបណ្តើរស្ត្រីស្រាតខ្លួនទទេម្នាក់ព្រមទាំងមានកូនក្មេងតូចមួយដើរតាមក្រោយផង។ គាត់ស្គាល់ច្បាស់នាងជាប្រពន្ធរបស់យុទ្ធ។ ភ្លាមនោះគាត់ឃើញគេទាញកាំបិតចុងស្រួចយារចាក់ទៅលើស្ត្រីនោះ គាត់ក៏ងាកមុខចេញ។ ពេលគាត់ងាកមកម្តងទៀតឃើញគេចាប់គ្រវែងក្មេងតូចនោះចូលរណ្តៅ។ គាត់មិនឮសម្លេងអ្វីទេ ហើយគាត់ក៏មិនសួរដេញដោលរឿងនោះដែរ។ គាត់គ្រាន់តែយល់ថាទីនោះជាកន្លែងគេសម្លាប់មនុស្ស និងជឿថានាងពិតជាត្រូវពួកគេទាំងនោះទើបរំលោភរួច ហើយនាំមកសម្លាប់ខណៈដែលគាត់មកដល់ដែរ។ ចំពោះជនល្មើសទាំងនោះវិញគាត់មិនដឹងថាគេមានវាសនាយ៉ាងណាទេ។



លោក សាត ភាព

## អារម្មណ៍ និងការចងចាំ

គាត់តូចចិត្តដោយខំតស៊ូរហូតធ្លាក់ខ្លួនពិការ ក៏ប៉ុន្តែពួកខ្មែរក្រហមទាំងនោះនៅតែតាមសម្លាប់ពួកគាត់ទៀត គេចោទថាពួកគាត់ក្បត់។ គាត់រស់នៅទាំងភ័យខ្លាចឥតឈប់ឈរ ពួកខ្មែរក្រហមសម្លាប់មិនរើសមុខទេ។ គាត់មានការរន្ធត់ណាស់ដែលបានឃើញការសម្លាប់ប្រពន្ធមិត្តគាត់ម្នាក់នេះចំពោះមុខ។

គាត់ធ្លាប់និយាយរឿងនោះប្រាប់គេច្រើនគ្នាដែររួមទាំងអ្នកភូមិដែលគាត់រស់នៅសព្វថ្ងៃ។ ពួកគេជឿថានៅរបបខ្មែរក្រហមនោះមិនមែនគ្រាន់តែសម្លាប់ទេ ពិតជាមានការរំលោភជាពិសេសលើស្ត្រីដែលស្អាតៗ។ ដើម្បីជាការចងចាំទី១ គឺចងក្រងជាសៀវភៅដូចដែលយើងកំពុងធ្វើនេះ។ ទី២ ត្រូវឧស្សាហ៍ដំណាល ឬនិយាយប្រាប់ក្មេងៗ និងត្រូវចែករំលែកនូវរឿងទាំងនោះបន្ត។

# សែប ភាព

អាយុ៥២ឆ្នាំ សព្វថ្ងៃរស់នៅ ស្រុកទ្រាំង ខេត្តតាកែវ ធ្វើស្រែ
មានស្វាមីជាគ្រូបង្រៀន មានកូន៣នាក់។

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រីភាព នៅឃុំរការក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ជានារីកងចល័តធ្វើជានារសារប្រធាននារីឃុំ និងប្រធានកងនារី។ គាត់បានដឹងរឿងហិង្សាផ្លូវភេទចំនួន២។ រឿងទី១នោះកើតឡើងនៅឆ្នាំ១៩៧៦ រវាងនារីម្នាក់ឈ្មោះខុម អាយុប្រហែល២២ឆ្នាំ នៅលីវ ជាប្រធាននារីឃុំ និងបុរសម្នាក់ឈ្មោះមាឃ ជាប្រធានឃុំ មានប្រពន្ធ និងកូនចំនួន៥នាក់។ គាត់ឧស្សាហ៍ឃើញឈ្មោះមាឃមកហៅនារីខុមនៅវេលាយប់ចេញទៅក្រៅជាញឹកញាប់ តែគាត់ក៏មិនដឹងថាមានរឿងអ្វីកើតឡើងទេ។ ថ្ងៃមួយនោះគាត់និយាយទៅកាន់ឈ្មោះមាឃថា:"អ៊ីឯងម៉េចក៏អាសារមកហៅបងខ្ញុំទាំងយប់អញ្ជើង? បុរសនោះឆ្លើយថា:"កុំចេះមាត់ប្រយ័ត្នអញអារកក្រវាត់ចោល"។ ក្រោយមកគាត់បានដឹងថានារីខុមមានផ្ទៃពោះឧស្សាហ៍ក្អួតចង្អោរ ហើយនារីខុមនោះក៏ប្រាប់គាត់ថាខ្លួនកំពុងមានផ្ទៃពោះ និងហាមគាត់មិនឱ្យនិយាយប្រាប់គេទេ។ នារីខុមព្យាយាមលេបថ្នាំសម្លាប់ខ្លួនជាច្រើនដង និងនិយាយថា:"គង់ថ្ងៃណាមួយគេនឹងសម្លាប់បងទេ"។ មានថ្ងៃមួយនារីខុមបានលេបថ្នាំសម្លាប់ខ្លួនមែន។ គាត់បានហៅគេឯងឱ្យជួយយកនារីខុមទៅពេទ្យបានពាក់កណ្តាលផ្លូវនារីខុមក៏ដាច់ខ្យល់ស្លាប់។ មួយអាទិត្យក្រោយមកគេបានចាប់ឈ្មោះមាឃនោះយកទៅសម្លាប់ដែរ ដោយចោទថាខុសសីលធម៌ជាមួយនារីខុម។

រឿងទី២ ក្រោយពីនារីខុមស្លាប់ទៅគាត់បានមកធ្វើជានារសាររបស់មេកងនារីម្នាក់ផ្សេងទៀតនៅវត្តតុំ ក្នុងឃុំដូនកែវ។ មាននារីម្នាក់ឈ្មោះសៀប មានអាយុប្រហែល២០ឆ្នាំ មានសម្រស់ស្អាតជាងគេក្នុងកងនារី។ នារីសៀប ត្រូវប្រធានយោធាម្នាក់ឈ្មោះណាត ស្នើសុំមកប្រធានកងគាត់ដើម្បីរៀបការ តែត្រូវប្រធានកងគាត់បដិសេធថានារីសៀប មានគេស្នើរួចហើយ។ ថ្ងៃមួយនៅម៉ោងប្រហែល១២អធ្រាត្រ មានមនុស្សប្រុស៣នាក់មករកប្រធានកងគាត់ហើយសួររកនារីសៀប។ បុរស៣នាក់នោះបាននាំនារីសៀបចេញទៅទាំងយប់មកចំងាយប្រហែល៥០០ម៉ែត្រពីវត្តតុំ។ បុរសទាំង៣នាក់នោះគ្មានកាំភ្លើងទេមានតែដំបង។ យប់នោះវេនគាត់យាមមានទាំងកាំភ្លើងមួយដើមផង គាត់ក៏ហៅមិត្តគាត់ម្នាក់ឈ្មោះយ៉ុងដើម្បីតាមដាន។ ពេលទៅដល់ក្បែរកន្លែងកើតហេតុ គាត់បានរំកិលខ្លួនចូលជិតបន្តិចម្តងៗរហូតចំងាយប្រហែល៥ម៉ែត្រប៉ុណ្ណោះ។ ពួកគេមើលមិនឃើញគាត់ទេ ព្រោះគាត់នៅបាំងនឹងកូនត្នោតភ្លោះ២ដើម និងមានកូនសង្កែតូចៗនៅក្បែរនោះផង។ គាត់បានឃើញគេចាប់ហែកអាវនារីសៀបរួចផ្តេកទៅលើដី នាងបានសុំអង្វរពួកគេថា: "ធ្វើអ្វីក៏ធ្វើទៅសុំកុំសម្លាប់ខ្ញុំ ហើយខ្ញុំក៏មិនរាយការណ៍អំពីរឿងនេះដែរ"។ គាត់បានឮសំឡេងនារីសៀបយំ ហើយពួកគេក៏បានយកអ្វីមកញ៉ុកមាត់នារីសៀប។ ពួកគេបានរំលោភនារីសៀបទាំង៣នាក់ បន្ទាប់មកគេបានវាយនាងនឹងដំបង។ ដោយខ្លាចមិនទាន់ស្លាប់ពួកគេ បានទៅយកធាងត្នោតមកអាករបន្ថែមទៀត។ រយៈពេលប្រហែលជាង១ម៉ោងគាត់ និងមិត្តគាត់ក៏ត្រឡប់មកកន្លែងវិញ។ ថ្ងៃស្អែកឡើងគាត់ដើរទៅទីនោះ គាត់បានឃើញធាងត្នោតមានប្រឡាក់ឈាម តែមិនឃើញសាកសពនារីសៀបទេ។



## អ្នកស្រី សែប ភាព

ចំពោះបុរសពនាក់ដែលរំលោភនារីសៀបនោះគាត់មិនស្គាល់គេទេ។ ហើយក្រោយមកក៏មិនដឹងថាគេទាំងពនាក់នោះយ៉ាងណាដែរ។ ពីរបីថ្ងៃក្រោយមកយោធាម្នាក់ឈ្មោះណាតបានមកសួររកនារីសៀប។ គាត់ឃើញមេកងគាត់ឆ្លើយរតាក់រតុបមិនដឹងថាម៉េចខ្លះទេ។ ក្រោយមកគេក៏បានចាប់ប្រធានកងគាត់នោះទៅបាត់។

## អារម្មណ៍ និងការចងចាំ

ពេលឃើញហេតុការណ៍គេធ្វើមកលើនារីសៀប គាត់មានអារម្មណ៍ថាខ្លាចគេធ្វើបាបយ៉ាងដូច្នោះដែរ។ គេមិនគួរធ្វើបាបនារីដូចសត្វធាតុសោះ ពួកគេមិនសមជាមនុស្សទេ។ ពួកគេគួរតែគិតថាគេមានម្ដាយ ឬមានបងប្អូនស្រីដែរ។ ទោះជារំលោភហើយ គួរទុកជីវិតឱ្យគ្នាផងដែលគ្នាសុំអង្វរនោះ។ បើនាងនៅរស់ម្លេះសព្វថ្ងៃនាងមានវាសនាល្អហើយ។

គាត់ធ្លាប់និយាយជាមួយអ្នកដែលធ្លាប់ដឹងរឿងទាំងនោះខ្លះដែរ។ គាត់ក៏ធ្លាប់និយាយរឿងនោះដល់ក្មេងស្រីៗ។ ក្មេងៗទាំងនោះសរសើរថាគាត់ថាបានរស់នៅហើយយករឿងទាំងនោះមកចែកពួកគេបានដឹង។ គាត់ចង់ឱ្យក្មេងៗទាំងនោះដឹងនូវទុក្ខវេទនា និងការធ្វើបាបមកលើស្ត្រី។ ជាការចងចាំគាត់ថាយើងត្រូវតែនិយាយរឿងនោះ និងដើម្បីកុំឱ្យរឿងបែបនោះកើតមានដូច្នេះទៀត។

# សុន ពៅ[1]

អាយុ៤៨ឆ្នាំ ធ្វើស្រែ និងស៊ីឈ្នួលគេ រស់នៅខេត្តកណ្ដាលមានបងប្អូន៨នាក់ ប្រុស៤ ស្រី៤នៅរស់៣នាក់។

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រី ពៅ នៅក្នុងខេត្តកណ្ដាល ធ្វើស្រែ ជីកប្រឡាយ រែកដី នៅកងចល័តនារី។ គាត់បានជួបនូវរឿងហិង្សាផ្លូវភេទមកលើខ្លួនគាត់ផ្ទាល់ក្នុងរបបខ្មែរក្រហមចំនួន២លើក ជាបន្តបន្ទាប់គ្នាក្នុងឆ្នាំ១៩៧៧ខណៈគាត់អាយុត្រឹម១៩ឆ្នាំ និងមិនទាន់គ្រប់ការផង។ ថ្ងៃមួយគេបានចាត់ឱ្យគាត់ទៅធ្វើការនៅស្រែជ្រៅពេលគាត់ទៅដល់ទីនោះគាត់មិនឃើញមានមនុស្សធ្វើការនៅទីនោះទេ។ គាត់ក៏ត្រឡប់មកវិញនៅតាមផ្លូវមានមនុស្សម្នាក់ចាប់រំលោភគាត់នៅម៉ោងប្រហែល៩ល្ងាចនៅក្នុងភូមិខ្លាលោត ឃុំកំពង់កុង ស្រុកកោះធំ។ គេនោះឈ្មោះមាន អាយុប្រហែល២០ឆ្នាំ ជានារសារប្រធានវរៈ។ ដំបូងគាត់បានអង្វរឱ្យគេលែងរូបគាត់ តែគេមិនព្រមហើយគេបានវាយលើពោះគាត់ ធ្វើឱ្យគាត់ចុកយ៉ាងខ្លាំងរួចគេចាប់ផ្ដើមដោះសំលៀកបំពាក់ និងរំលោភគាត់នៅក្នុងព្រៃ។ គេរំលោភគាត់ហើយគេទុកគាត់ចោលទីនោះដោយគ្មានសំលៀកបំពាក់ជាប់នឹងខ្លួនទេ។ គាត់ឃើញមនុស្សចាស់២នាក់ដើរត្រឡប់មកពីធ្វើការវិញ គាត់បានស្រែកសុំឱ្យតា២នាក់នោះជួយ។ តាទាំង២នាក់នោះបានគ្រារូបគាត់មកកាន់កន្លែងកងនារីដែលមានចំងាយប្រហែលមួយគីឡូម៉ែត្រពីកន្លែងរំលោភ។ តាទាំង២នាក់ទុករូបគាត់នៅក្បែរកន្លែងកងនារី ហើយពួកគាត់ក៏ចាកចេញទៅភូមិវិញទៅ។ តាទាំង២នាក់នោះជាអ្នករស់នៅក្នុងភូមិរបស់គាត់ម្នាក់ឈ្មោះម៉ុន ហើយម្នាក់ទៀតគាត់មិនចាំឈ្មោះទេ។

នៅម៉ោងប្រហែល៦កន្លះល្ងាច មេកងនារីឈ្មោះគឹម បានសួរដេញដោលគាត់ថាទើបមកពីណា។ គាត់បានប្រាប់រឿងឈ្មោះមាន ធ្វើបាបគាត់ តែផ្ទុយទៅវិញគាត់ត្រូវមេកងទះកំភ្លៀង ហើយបន្ទោសថាចេះតែឆ្លើយដាក់គេឯងផ្ដេសផ្ដាស។ គាត់ត្រូវគេចាប់ចងមុខជិតយកទៅដាក់ក្នុងខ្ទមមួយដែលគេបោះបង់ចោល និងចងដៃទៅក្រោយភ្ជាប់ទៅនឹងសរសរខ្ទមនោះ។ នៅម៉ោងប្រហែល៩យប់ គាត់ដឹងថាមានមនុស្សប្រុស២នាក់បានទៅរកគាត់។ គេបានស្រាយចំណងដៃគាត់ ដែលចងភ្ជាប់បង្គោលសរសររោង តែគេមិនស្រាយកន្សែងរំមុខគាត់ទេ។ គាត់បានសុំអង្វរគេថាកុំធ្វើបាបគាត់ តែពួកគេបានឆ្លើយថាៈ "ទោះបីម៉ែឯងមកអង្វរក៏មិនព្រមដែរ " ហើយគំរាមគាត់ថានៅឱ្យស្ងៀមកុំមាត់ប្រយ័ត្នស្លាប់ រួចគេចាប់រំលោភគាត់តែម្ដង។ គាត់មិនចាំថាគេធ្វើអ្វីខ្លះមកលើរូបគាត់ទេ ពេលនោះដោយគាត់ត្រូវសន្លប់ជាច្រើនម៉ោង គាត់ក៏មិនអាចមើលឃើញមុខអ្នករំលោភគាត់ដែរ តែគាត់ស្គាល់សម្លេងមនុស្សម្នាក់ឈ្មោះមាន ដែលរំលោភគាត់ពីពេលថ្ងៃ។ គេបានទុកគាត់ចោលនៅទីនោះតែម្នាក់ឯងរហូតជិតភ្លឺទើបគាត់ដឹងខ្លួន។ មាននារីពេទ្យម្នាក់ឈ្មោះយេត យាមយប់ឮសម្លេងគាត់ស្រែកថ្ងូរអំពីការឈឺចាប់ក៏ដើរចូលទៅរោងនោះ ហើយក៏ជួយស្រាយចំណងគាត់ និងនាំគាត់មកព្យាបាលស្ងាត់ៗ។ ក្រោយមកគាត់ក៏រត់មកនៅសហករណ៍ផ្សេង។

ចំពោះជនល្មើសឈ្មោះមាននោះ គាត់មិនដឹងថាមានវាសនា និងរស់នៅទីណាទេសព្វថ្ងៃ។ ចំពោះតាម៉ុនដែលបានជួយគាត់នោះបានស្លាប់កាលពីឆ្នាំ១៩៨៦ហើយ។ ចំពោះពេទ្យយេតទើបតែស្លាប់ប៉ុន្មានឆ្នាំនេះទេ ហើយគាត់ក៏ឱស្សាហ៍រាប់រកគ្នាកន្លងមកដែរ។

[1] ជាឈ្មោះក្លែង



## អ្នកស្រី សុន ពៅ

## អារម្មណ៍ និងការចងចាំ

គាត់មានការខ្មាស់អៀននឹកចង់សម្លាប់ខ្លួនជាញឹកញាប់ និងមានការតូចចិត្ត។ តែគាត់រស់មកដល់សព្វថ្ងៃ ដោយសារការលើកទឹកចិត្តពីឪពុកគាត់ថា:"កូនត្រូវតែរស់តទៅទៀត"បើមិនមានរឿងបែបនេះកើតឡើងមកលើរូបគាត់ គាត់ប្រហែលមានគ្រួសារមានអនាគតភ្លឺស្វាងនឹងគេហើយ។ គាត់មិនចង់មើលខ្សែភាពយន្តរឿងរំលោភទេ គាត់មានអារម្មណ៍ក្តុកក្តួលខ្លាំងណាស់។

អ្នកខ្លះបានដឹងរឿងគាត់គេក៏មានការអាណិតអាសូរគាត់ដែរ។ គាត់សំរេចនិយាយរឿងគាត់ថ្ងៃនេះមានបំណងថា សូមកុំឱ្យមានរបបនេះកើតឡើងសាជាថ្មីព្រោះវាសាហាវណាស់។ គាត់ក៏មានបំណងថា កុំឱ្យអំពើបែបនេះកើតមានមកលើក្មេងៗជំនាន់ក្រោយទៀត គាត់ចង់ឱ្យចងក្រងរឿងទាំងនេះទុកដើម្បីឱ្យមនុស្សជំនាន់ក្រោយបានដឹង។

# ប្រាក់ យឹន

អាយុ៦៣ឆ្នាំ ជាស្ត្រីមេម៉ាយ ធ្វើស្រែរស់នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងឆ្នាំ១៩៧២ គាត់ចូលរួមក្នុងចលនាតស៊ូរបស់ខ្មែរក្រហម តាមការអំពាវនាវរបស់ក្រុមនេះនៅស្រុកឱរ៉ាល់

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រី យឹន រស់នៅខេត្តកំពង់ស្ពឺដែលដឹកនាំក្រុមនារីធ្វើស្រែ លើកទំនប់ ជាអ្នកទោស (ជាប់គុក) ធ្វើសេដ្ឋកិច្ច និងជាចុងភៅ។ គាត់ត្រូវពួកខ្មែរក្រហមចាប់ដាក់គុក ហើយត្រូវជួបនូវរឿងហិង្សាខាងផ្លូវភេទចំនួន២ករណី។ ទី១ គឺការបៀតបៀនខាងផ្លូវភេទដោយសន្តិសុខនៅយាមគុក និងទី២ គឺការបង្ខំឱ្យរៀបការនៅពេលគាត់ជាប់គុក។ នៅចុងឆ្នាំ១៩៧៦ គាត់ត្រូវគេចាប់ដាក់គុកនៅភ្នំប្រសិទ្ធិ ក្នុងស្រុកឧដុង្គ។ គេចោទថាគាត់ក្បត់អង្គការ និងខុសសីលធម៌។ គាត់ត្រូវគេធ្វើទារុណកម្មឆក់ខ្សែភ្លើង និងច្រកស្បោងផ្លាស្ទិក។ គាត់ថា នៅវេលារសៀលថ្ងៃទី២នៃការជាប់គុករបស់គាត់មានសន្តិសុខម្នាក់ឈ្មោះវុន អាយុប្រហែល ២៦ឆ្នាំបានចូលមករកគាត់មានស្លៀកខោខ្លី និងយកកាំភ្លើងមកជាមួយផង ខណៈគាត់នៅម្នាក់ឯង។ គាត់ថាមនុស្សនេះហាក់មានអារម្មណ៍ដូចជាញាប់ញ័រនឹងអ្វីម្យ៉ាង ហើយបាននិយាយសុំរួមភេទជាមួយគាត់ គេក៏បានយកប្រដាប់ភេទរបស់គេមកដាក់លើភ្លៅរបស់គាត់។ គាត់បានឆ្លើយថា: "រូបខ្ញុំជាអ្នកទោស តើអ្នកឯងសុខចិត្តស្លាប់ជាមួយខ្ញុំទេ?" រួចសន្តិសុខរូបនោះក៏ចេញទៅវិញទៅ។





អ្នកស្រី ប្រាក់ យឹន







ក្រោយពីការជាប់គុកប្រហែលជាង១០ថ្ងៃ គេអនុញ្ញាតឱ្យគាត់ចេញមកខាងក្រៅធ្វើស្រែ និងក្រោយមកធ្វើជាចុងភៅ តែនៅស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកទទួលខុសត្រូវនៅក្នុងគុកនេះដដែលរហូតឆ្នាំ១៩៧៩។ នៅទីនោះគាត់បានដឹងថា ឈ្មោះវុននេះ មានរឿងខុសសីលធម៌ជាមួយនារីវឿន និងលូកលាន់លើនារីផ្សេងទៀត តែគាត់មិនឃើញមានរឿងអ្វីកើតឡើងចំពោះរូបគេទេ។ ក្រោយឆ្នាំ១៩៧៩ គាត់ក៏មិនដឹងថាមានរឿងអ្វីចំពោះឈ្មោះវុនទេ ហើយសព្វថ្ងៃក៏មិនដឹងថាគេរស់នៅទីណាដែរ។

ឆ្នាំ១៩៧៧ នៅក្នុងគុកប្រសិទ្ធិនេះគាត់ត្រូវរៀបការចំនួន២គូ។ គេតម្រូវឱ្យគាត់រៀបការជាមួយមនុស្សម្នាក់ ឈ្មោះសុខ ធ្វើការនៅក្នុងគុកនោះដែរ។ ការរៀបការរបស់គាត់ធ្វើឡើងនៅពេលយប់ក្នុងរយៈពេលដ៏ខ្លី។ ក្រោយការរៀបការភ្លាមគេតម្រូវឱ្យគាត់ទៅតាមកន្លែងដែលបានកំណត់ហើយត្រូវតែរួមភេទនៅពេលនោះឯង។ គាត់ធ្លាប់ឃើញប្ដីគាត់ដែរ តែមិនដែលនឹកថាចង់រៀបការជាមួយម្ដងណាទេ។ គាត់មិនហ៊ានប្រកែកនឹងការរៀបការនោះទេ ហើយក៏មិនហ៊ានប្រកែកនឹងការរួមភេទដែរ ព្រោះគាត់នឹកឃើញពេលគាត់ជាប់គុកបាននិយាយថាគោរពនិងធ្វើតាមអង្គការទាំងអស់។ ក្នុងការរស់នៅជាមួយគ្នា ប្ដីគាត់តែងតែប្រច័ណ្ឌ និងប្រើហិង្សាមកលើគាត់។ គាត់មិនដែលហ៊ានរាយការណ៍ពីប្ដីគាត់ទេ តែមានពេលមួយនោះគាត់ត្រូវគេប្រាប់ថាប្ដីគាត់ត្រូវអង្គការយកទៅកសាងប្រហែលមានគេដឹងរឿងនោះ។ ក្រោយមកទៀតប្ដីគាត់នៅតែប្រើហិង្សាមកលើគាត់ដដែល។ មានថ្ងៃមួយប្ដីគាត់បានយកកូនកាំបិតតូចមកចាក់លើរូបគាត់ គាត់បានរើបំរាស់ឱ្យគេជួយតែប្ដីគាត់ចាក់ត្រូវគាត់រហូតមានស្នាមដល់សព្វថ្ងៃ។ កុំតែមានគេជួយគាត់មិនដឹងជាយ៉ាងណាទេ។ គេក៏បានយករូបគាត់ទៅទុកកន្លែងមានសុវត្ថិភាព។ ប្ដីគាត់បាននិយាយថាថ្ងៃក្រោយឈប់ធ្វើដូច្នោះទៀតហើយ រួចគេបានយកប្ដីគាត់ទៅបាត់រហូត។ គាត់គិតថាប្ដីគាត់ពិតជាស្លាប់ហើយ ហើយគាត់ក៏បែកគ្នាតាំងពីពេលនោះមក។





## អារម្មណ៍ និងការចងចាំ

គាត់មានអារម្មណ៍តូចចិត្តជាខ្លាំងត្រូវគេមើលងាយខាងផ្លូវភេទ និងរាងកាយ ត្រូវគេបង្ខំឱ្យរៀបការទាំងយប់គ្មានបងប្អូនញាតិមិត្ត និងរៀបការជាមួយមនុស្សដែលគាត់មិនស្រឡាញ់ត្រូវគេធ្វើបាបទៀត។ ប្រសិនគាត់បានជ្រើសរើសប្ដីដោយខ្លួនឯងគាត់ប្រហែលមានអនាគតប្រសើរជាងនេះ។

គាត់មិនបានលាក់បាំងរឿងរ៉ាវរបស់គាត់ទេ។ គាត់បាននិយាយរឿងទាំងអស់នេះប្រាប់អ្នកភូមិ ឬអ្នកដែលបានឆ្លងកាត់របបខ្មែរក្រហមដូចគ្នា នូវអ្វីដែលគាត់បានជួបប្រទះ ហើយពួកគេជឿរឿងទាំងនោះ។ ការនិយាយរបស់គាត់នៅពេលនេះគឺចង់ឱ្យមនុស្សផ្សេងទៀតបានដឹង ជាពិសេសក្មេងៗជំនាន់ក្រោយដែលគេមិនសូវដឹង និងមិនសូវបាននិយាយប្រាប់ពួកគេទាំងនោះ។

# ទឹម ទូច

អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង មានព្រន្ធកូន៦នាក់ ប្រុស៤ ស្រី២ មានមុខងារជាសមាជិកក្រុមប្រឹក្សាឃុំ មុនរបបខ្មែរក្រហម ធ្វើទាហានលន់ នល់ ហើយត្រឡប់មករស់នៅបាត់ដំបង វិញនៅឆ្នាំ១៩៧៤

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោក ទូច នៅស្រុកបាណន់ ខេត្តបាត់ដំបង ធ្វើស្រែ គ្រប់គ្រងកុមារធ្វើជី ធ្វើចំការ និងធ្វើស្រែ។ គាត់បានរៀបការនៅពាក់កណ្តាលឆ្នាំ១៩៧៥។ គាត់ដូចជាសំណាងបន្តិច ព្រោះការរៀបការរបស់គាត់ពេលនោះធ្វើឡើងតែមួយគូទេ មានញាតិមិត្ត ឪពុកម្តាយ ព្រះសង្ឃ អាចារ្យនិង មានបងប្អូនចូលរួមទាំងសងខាងប្រហែល២០នាក់។ មានដាំបាយ ធ្វើម្ហូបមានមាន់ ទា ជ្រូក ព្រោះគេមិនទាន់ប្រមូលយកទៅដាក់រួមនៅឡើយ។ តែគាត់ថាក៏គ្មានអ្វីធំដុំដែរមិនមាន ភ្លេងបុរាណ សម័យ និងគ្មានមេក្រូ ឬការរាំច្រៀងអ្វីទេ។ ការសំរេចចិត្តរៀបការរបស់គាត់គឺទៅតាមចាស់ទុំផ្សំផ្គុំ ហើយក៏ដើម្បីបានរស់នៅក្បែរម៉ែឳ និងរួចពីការធ្វើជាកងចល័តទៅឆ្ងាយពីផ្ទះ។ គាត់ថាចាប់ពីឆ្នាំ១៩៧៦មក ការរៀបការត្រូវធ្វើឡើងច្រើនគូក្នុង១លើក២ ដែលចាត់ចែងដោយអង្គការ។

ក្រៅពីរឿងរៀបការរបស់គាត់ លោកទូចបានឃើញនូវអំពើហិង្សាផ្លូវភេទមួយករណីនៅក្រោយថ្ងៃរំដោះដើមឆ្នាំ១៩៧៩។ គាត់បានឃើញផ្ទាល់ភ្នែកនូវសាកសពគេសម្លាប់ប្រមាណជាង២០នាក់ មានចាស់ក្មេង ស្រីប្រុស នៅកណ្តាលវាលស្រែម្តុំបឹងម្កាក់ ឃុំស្ទឹងក្នុងស្រុកបាណន់។ សពទាំងនោះរាងគ្រៀមបន្តិចដោយសារកំដៅថ្ងៃ។ គាត់ជឿថាសពស្ត្រីម្នាក់ដែលគាត់មិនស្គាល់អត្តសញ្ញាណនោះត្រូវគេរំលោភមុនសម្លាប់។ ស្ត្រីនោះមានអាយុប្រហែលជាង២០ឆ្នាំ ស្ថិតនៅដាច់ឆ្ងាយពីគេប្រហែល៣០ម៉ែត្រ ក្បែរគុម្ពោតព្រៃមួយប្លែកពីសពដទៃស្រាតគ្មានខោអាវមានតែខោទ្រនាប់ជាប់នៅជើងម្ខាង ដេកផ្ងា កន្ធែកជើងទៅខាង ដៃទាំងពីរសន្ធូកទៅលើ ហើយក្រៅពីនោះក៏មានខោអាវជារបស់ស្ត្រីនោះនៅក្បែរ២ដែរ។ គាត់ជឿថាជាការរំលោភមុនសម្លាប់ ហើយជាស្នាដៃរបស់ពួកខ្មែរក្រហម ព្រោះកន្លែងនោះជាផ្នែកដែលនៅកាន់កាប់របស់ពួកនោះនៅឡើយ។ ជនរងគ្រោះទាំងនោះ ជាប្រជាជនអាចរត់មកកាន់ទីរួមខេត្តបាត់ដំបង ហើយជួបនឹងពួកខ្មែរក្រហមតាមផ្លូវក៏សម្លាប់ និងធ្វើបាបតែម្តង។ គាត់បញ្ជាក់ថានៅខែមករា១៩៧៩ ក្រុងបាត់ដំបងត្រូវរំដោះហើយ ប៉ុន្តែនៅតាមតំបន់ជាយ២ក្រុង នៅមានការប្រទុងប្រទាញគ្នារវាងកងទ័ពវៀតណាម និងពួកខ្មែរក្រហមនៅឡើយ។ លោកទូចនិយាយថាៈ "ពួកខ្មែរក្រហមពិតជាមិនអត់ឱនឱ្យអ្នកណាម្នាក់រួចខ្លួនឡើយ បើជួបពួកវាពេលធ្វើដំណើរមករកខាងវៀតណាម ឬកងទ័ពហេងសំរិននៅពេលនោះ"។

## អារម្មណ៍ និងការចងចាំ

គាត់មានការរន្ធត់យ៉ាងខ្លាំងដោយឃើញហេតុការណ៍ទាំងនោះ។ គាត់ថាតើមុននឹងស្លាប់ តើគេធ្វើបាបអ្នកទាំងនោះយ៉ាងណាខិតខំមករករស់បែរជាស្លាប់យ៉ាងអាណោចអាធ័មបែបនេះ។ គាត់ក៏ធ្លាប់បាននិយាយរឿងនេះប្រាប់គេឯងដែរ។ ការផ្តល់ព័ត៌មានទាំងនេះ គាត់យល់ថា មានតំលៃដើម្បីឱ្យមនុស្សជំនាន់ក្រោយ ឬអ្នកផ្សេងទៀតបានដឹងថាមានអំពើហិង្សាខាងផ្លូវភេទនេះកើតឡើងច្រើនបែបច្រើនយ៉ាងណាស់ពេលស្រុកមានសង្គ្រាមយ៉ាងនោះ។



លោក ទឹម ទូច







# ទង កែវ[១]

អាយុ៧៦ឆ្នាំ ជរានៅផ្ទះ រស់នៅស្រុកកំពង់ត្រាច ខេត្តកំពត
ជាស្ត្រីមេម៉ាយ មានកូន៤នាក់

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកយាយ កែវ នៅដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត គាត់ធ្វើស្រែ ចិញ្ចឹមសត្វនាង និងធ្វើការកសិកម្មគ្រប់បែបយ៉ាង។ ប្ដីគាត់ត្រូវខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៣។ គាត់ត្រូវអ្នកទទួលខុសត្រូវខ្មែរក្រហមម្នាក់ប្រព្រឹត្តហិង្សាផ្លូវភេទមកលើរូបគាត់ផ្ទាល់។ នៅរដូវប្រាំងក្នុងឆ្នាំ១៩៧៥ ពេលយប់មួយនោះប្រធានភូមិខ្មែរក្រហមបានមករកគាត់ ខណៈគាត់កំពុងដេកលក់ជាមួយកូនប្រុសតូចគាត់ម្នាក់។ ពេលមកដល់នៅដៃរបស់គេមានកាន់កាំបិតមកជាមួយផង ហើយគេបានគំរាមគាត់មិនឱ្យស្រែក ឬមាត់កអ្វីទាំងអស់។ ដោយខ្លាចគេធ្វើបាបទៅថ្ងៃក្រោយគាត់ក៏ទ្រាំទៅ គេក៏រំលោភគាត់បានសំរេចពេលនោះ។ ថ្ងៃក្រោយមកជននេះនៅតែមកធ្វើបាបគាត់ជាបន្តបន្ទាប់ គាត់បានអង្វរទៅជនល្មើសនោះថាឈប់មកធ្វើបាបគាត់ទៀត តែគេមិនស្ដាប់គាត់ឡើយ។

ពេលរូបគាត់មានផ្ទៃពោះ គាត់ក៏បាននិយាយប្រាប់អ្នកធ្វើការជាមួយគ្នា។ គេបានចាត់ពេទ្យម្នាក់ឈ្មោះរឿនឱ្យមកពិនិត្យថាតើគាត់មានផ្ទៃពោះពិតមែនទេ។ ក្រោយមកជននេះក៏ឈប់មករកគាត់។ រូបគាត់ត្រូវគេចាប់ដាក់គុកនៅដំណាក់កន្ទួតចំនួន៣ខែ ទើបដោះលែងតែឱ្យធ្វើការធ្ងន់ៗនៅទីនោះ។ ចំពោះជនល្មើសជាប្រធានភូមិរបស់គាត់ ឈ្មោះសន មានអាយុប្រហែលជាង៤០ឆ្នាំ និងមានប្រពន្ធកូនរួចហើយ។ ជននេះក៏ត្រូវគេចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរឃុំឃាំងនៅតំណាក់កន្ទួតដូចគាត់ដែរ។ ក្រោយមកគេបញ្ជូនជននេះមកខេត្តកំពតបន្តទៀត រួចគាត់ឮថាគេសម្លាប់ជននេះហើយ។

## អារម្មណ៍ និងការចងចាំ

ពេលរឿងនោះកើតឡើងថ្មីៗ គាត់មានការឈឺចាប់ជាខ្លាំង ដោយគេចាប់រំលោភគាត់ហើយ ពួកខ្មែរក្រហមនេះចាប់គាត់ដាក់គុកទៀតមិនជួយរកខុសត្រូវឱ្យគាត់ទេ។ គាត់បានបន់ស្រន់ថាបើគាត់ធ្វើល្អសូមឱ្យគាត់ជួបតែអំពើល្អ អ្នកធ្វើអាក្រក់ជួបអំពើអាក្រក់។ ប្រហែលដូចគាត់បន់មែនជននេះត្រូវគេចាប់យកទៅសម្លាប់។ គាត់មិនដែលនិយាយរឿងនេះប្រាប់អ្នកណាផ្សេងទៀតទេ ក្រៅពីអ្នកដែលគាត់និយាយប្រាប់ខាងលើនៅរបបខ្មែរក្រហម។ តែគាត់ជឿថារឿងរបស់គាត់អាចមានមនុស្សនៅជំនាន់នោះដឹងច្រើនគ្នាដែរនៅក្នុងភូមិគាត់។

ចំពោះកូនប្រុសម្នាក់ដែលគាត់មានផ្ទៃពោះដោយជនល្មើសនោះ គេអាចនឹងដឹងរឿងទាំងនោះពីអ្នកជិតខាង ទោះគាត់មិននិយាយរឿងនោះប្រាប់គេដោយផ្ទាល់ក៏ដោយ។ គេក៏មិនដែលសួរនាំអ្វីមកគាត់ដែរ គេជាមនុស្សល្អ និងផ្ដល់ប្រាក់កាស់ខ្លះៗដល់រូបគាត់ដែរ ទោះគេរស់នៅឆ្ងាយ និងមានប្រពន្ធកូនហើយក៏ដោយ។ គាត់និយាយរឿងទាំងនេះដោយគាត់មានវ័យកាន់តែចាស់ ហើយក៏ចង់ឱ្យមនុស្សជំនាន់ក្រោយដឹងថារបបខ្មែរក្រហមនេះវាឃោរឃៅខ្លាំងណាស់។

[១] ជាឈ្មោះក្លែង



លោកយាយ ទង កែវ





# យ៉េន អាំណាស

អាយុ៦៨ឆ្នាំ មេម៉ាយ ជនជាតិខ្មែរអ៊ីស្លាម មុខរបរលក់នំ មានកូនស្រីម្នាក់ រស់នៅស្រុកដងទង់ ខេត្តកោះកុង

## រឿងរ៉ាវក្នុងរបបខ្មែរក្រហម

លោកស្រី អាំណាស នៅស្រុកព្រៃនប់ ក្រុងព្រះសីហនុ ធ្វើចំការដាំដំឡូង និងធ្វើស្រែ។ គាត់បានជួបនូវរឿងការប៉ុនប៉ងរំលោភផ្លូវភេទដោយយោធាម្នាក់បន្ទាប់ពីប្ដីគាត់ត្រូវគេយកទៅសម្លាប់។ នៅឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានចាប់ប្ដីគាត់យកទៅប្រហែល១៥ថ្ងៃ ក្រោយមកគាត់បានទៅសួរមនុស្សម្នាក់ឈ្មោះរឿនថា៖" តើប្ដីគាត់នៅទីណា ហើយថ្ងៃណានឹងត្រឡប់មកវិញ?" ឈ្មោះរឿនឆ្លើយថា៖"ឆ្អសិងហើយ" មានន័យថាស្លាប់ហើយ។ ទន្ទឹមនឹងនោះឈ្មោះផន ជាយោធាម្នាក់ទៀតបានបន្ថែមថាខ្លួនគេនេះឯងជាប្ដីគាត់ហើយ។ នៅយប់ថ្ងៃដដែលពេលគាត់កំពុងដេកលក់ជាមួយកូនពៅគាត់អាយុប្រហែល៦ឆ្នាំ ឈ្មោះផននេះបានលបចូលមកបើកមុងគាត់។ ពេលនោះគាត់ភ្ញាក់ឡើងក៏សួរថានរណាគេហ្នឹង? ឈ្មោះផនឆ្លើយថាគេឈ្មោះផនហើយជាប្ដីគាត់ រួចគេចាប់សង្កត់លើគាត់ជាប់តែម្ដង។ គាត់ខំរើបំរាស់ និងរកមធ្យោបាយដោះស្រាយ។ គាត់រាវៗទៅប៉ះកូនគាត់នៅក្បែរនោះ គាត់ក៏ក្ដិចជើងកូនគាត់ឱ្យយំឡើងហើយស្រែករកគាត់។ ឈ្មោះផននោះក៏ឈប់សង្កត់គាត់ គាត់មានឱកាសរុញមនុស្សរូបនេះចេញដែរ។ ទន្ទឹមនឹងនោះគាត់ស្រែកប្រាប់គេឯងក្បែរខាងថាមានមនុស្សចូលមកផ្ទះគាត់។ មានមនុស្សផ្អើលឆោឡោឡើង ហើយឈ្មោះផននេះក៏គេចខ្លួនទៅបាត់ទៅ។

ថ្ងៃស្អែកឡើងមេរបស់ឈ្មោះផនមកសួរគាត់ថា ផនមានមកទីនេះទេ គាត់ឆ្លើយថា យប់មិញរូបគេនោះមករំខានគាត់។ បន្ទាប់មកគាត់ឮថាគេបានយកឈ្មោះផននេះទៅកសាង(អប់រំ)។ ឈ្មោះផននេះជាយោធាគាត់ទើបតែឃើញមកធ្វើការនៅទីនោះមួយរយៈខ្លីទេគេមានអាយុប្រហែល៣០ឆ្នាំ នៅលីវ។ ក្រោយមកទៀតឈ្មោះផននេះត្រូវគេឱ្យទៅកាប់ឈើ ហើយឈើសង្កត់ស្លាប់ទៅ។

## អារម្មណ៍ និងការចងចាំ

គាត់មានអារម្មណ៍ក្ដុកក្ដួលជាខ្លាំង ព្រោះបងប្អូន និងកូនបានស្លាប់ជាបន្តបន្ទាប់ ហើយប្ដីគាត់គេទើបតែយកទៅសម្លាប់ប្រមាណកន្លះខែ គាត់ពេលនោះមានអារម្មណ៍ភាំងៗជាញឹកញាប់។ ទោះបីមកដល់សព្វថ្ងៃក៏គាត់នៅតែនឹករលឹកដល់ប្ដីគាត់ដែរ។ ការដែលគេមកបំពានលើរាងកាយខណៈខ្លួនកំពុងសោកសៅយ៉ាងនេះ គឺសែនខ្លោចផ្សារមិនអាចបំភ្លេចបាន។

គាត់មិនដែលនិយាយរឿងនេះប្រាប់អ្នកណាទេ ព្រោះគិតថាជារឿងគួរឱ្យខ្មាសអៀន។ ពេលគាត់ចូលរួមវេទិការជាមួយដើមបណ្ដឹងរដ្ឋប្បវេណីនានា ហើយគេលើកទឹកចិត្តដល់អ្នកចូលរួមឱ្យបញ្ចេញមតិអំពីទុក្ខកង្វល់ផ្សេងៗ នៅក្នុងរបបខ្មែរក្រហមគាត់ក៏សំរេចនិយាយរឿងនោះចេញមក។ គាត់និយាយពេលនេះចង់ឱ្យមនុស្សទូទៅដឹងពីអំពើឃោរឃៅដែលពួកខ្មែរក្រហមធ្វើមកលើរូបគាត់ក៏ដូចអ្នកផ្សេងទៀត។



អ្នកស្រី យ៉េន អាំណាស







# សេចក្ដីសន្និដ្ឋាន

ការលាក់ទុកការឈឺចាប់ កាន់តែនាំមកនូវការឈឺចាប់ថែមទៀត និងមិនមានអ្នកណាអាចជួយអ្វីយើងបានឡើយ នេះជាទស្សនៈរួមរបស់ជនរងគ្រោះ និងសាក្សីស្ទើរតែទាំងអស់នៅក្នុងសៀវភៅនេះនិងប្រហែលជាសំរាប់មនុស្សទូទៅផងដែរ។ មិនតែប៉ុណ្ណោះព័ត៌មាន និងរឿងរ៉ាវជាប្រវត្តិសាស្ត្រក៏ត្រូវបាត់បង់ បើមិនមានការនិយាយចេញមករបស់ជនរងគ្រោះ និងសាក្សីនៅក្នុងសៀវភៅនេះទេ។ ផ្ទុយទៅវិញការដែលពួកគាត់ហ៊ាននិយាយចេញមកនេះ វាអាចជំរុញនិងលើកទឹកចិត្តដល់ជនរងគ្រោះ និងសាក្សីដ៏ទៃទៀតដែលបានលាក់ទុកការឈឺចាប់ជាយូរមកហើយហ៊ាននិយាយចេញមកដែរ។ ពួកគាត់អាចនឹងយល់ថា រឿងនេះមិនមែនកើតឡើងមកលើតែរូបគាត់ម្នាក់ឯងប៉ុណ្ណោះទេ ហើយគាត់មិនមែនជាអ្នកមានកំហុសដែរ។ ជនល្មើស ឬអ្នកប្រព្រឹត្តទេ ដែលខុសនឹងត្រូវដាក់ទណ្ឌកម្មពីច្បាប់ និងសង្គម។ ចំពោះរូបពួកគាត់គួរតែត្រូវបានទទួលការគោរពនិងទទួលស្គាល់ការឈឺចាប់នានាពីសំណាក់ក្រុមគ្រួសារ សហគមន៍ សង្គម និងមនុស្សជាតិទូទៅ។

# ការថ្លែងអំណរគុណ

ជាបឋមខ្ញុំសូមថ្លែងអំណរគុណ លោក សុក សំអឿន នាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលបានជួយផ្តល់នូវគំនិតសំខាន់ៗទាំងទស្សនៈផ្លូវច្បាប់ ទាំងផ្នែកសីលធម៌សង្គម និងការលើកទឹកចិត្តដល់រូបខ្ញុំផ្ទាល់ និងសហការីក្នុងការចងក្រងសៀវភៅនេះ។ ខ្ញុំសូមអរគុណ កញ្ញា បេនី យី ទីប្រឹក្សាជាន់ខ្ពស់ នៃគំរោងហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម ដែលបានផ្តល់នូវគំនិតល្អៗក្នុងការចងក្រងសៀវភៅនេះ និងចូលរួមមិនចេះនឿយហត់ក្នុងការចុះជួបជនរងគ្រោះ និងសាក្សីនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាពីដើមរៀងមក។ សូមអរគុណ លោកស្រី យឹម សុធារី និងកញ្ញា ហង្ស ចរិយា ដែលបានចំណាយកំលាំងកាយចិត្តចូលរួមសម្ភាសន៍ជនរងគ្រោះ និងសាក្សីកន្លងមក។ សូមអរគុណ លោកស្រី លាង ចរិយា និង កញ្ញា តុប កាន់តារា បានជួយពិនិត្យ និងកែអក្ខរាវិរុទ្ធ។ សូមអរគុណដល់ម្ចាស់មូលនិធិអង្គការ អូ អេស អាយ (OSI) ដែលបានផ្តល់មូលនិធិគាំទ្រក្នុងការស្រាវជ្រាវ និងបោះពុម្ពសៀវភៅនេះ។ ជាទីបញ្ចប់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក លោកស្រីជាជនរងគ្រោះ និងសាក្សីដែលបានចំណាយពេលវេលា និងផ្តល់ព័ត៌មានអំពីបទពិសោធន៍ផ្ទាល់ខ្លួនដ៏មានតំលៃមិនអាចកាត់ថ្លៃបាន សំរាប់ប្រវត្តិសាស្រ្ត និងមនុស្សជាតិទូទៅ ពិសេសមនុស្សជំនាន់ក្រោយ។ បើពុំមានការចូលរួមពីសំណាក់អស់លោក លោកស្រី និងអ្នកនាងកញ្ញា ព្រមទាំងម្ចាស់មូលនិធិទាំងអស់គ្នាទេ សៀវភៅនេះពិតជាមិនអាចលេចចេញជារូបរាងបានឡើយ។

អ្នកនិពន្ធ ដួង សាវ៉ន
មិថុនា-២០១១
អង្គការ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
អាស័យដ្ឋានផ្ទះលេខ:៥៥៧. ផ្លូវ៤៥០
ទួលទំពូង២
ខ.ចំការមន រាជធានីភ្នំពេញ
www.cdpcambodia.org
រចនារូបភាព និងអត្ថបទ : ក្រុមហ៊ុន មេឡុងរូស៍ / ហៀក វីឡា
melonrouge@melonrouge.asia
អ្នកគូររូប : វ៉ាឡង់ទីន ត្រាវ៉ាលី
អ្នកថតរូប : ស ច័ន្ទដារ៉ា
ឧបត្ថម្ភដោយ: វិទ្យាស្ថានសង្គមបើកទូលាយ

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT

OPEN SOCIETY
FOUNDATIONS

“ ការលាក់ទុកនូវការឈឺចាប់ កាន់តែនាំមកនូវការឈឺចាប់ថែមទៀត និងមិនមានអ្នកណាម្នាក់អាចជួយអ្វីយើងបានឡើយ ”

“ ពួកខ្មែរក្រហមគេបានទាញយកប្រយោជន៍ពីនារីភេទលើផ្នែកសម្ផស្សរាងកាយនេះសិន មុននឹងគេសម្លាប់ពួកនាង ”

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា : វិទ្យាស្ថានសង្គមបើកទូលាយ

CAMBODIAN DEFENDERS PROJECT : OPEN SOCIETY INSTITUTE